# ផ្នែកទី ១

# វគ្គបណ្តុះបណ្តាល

# ថ្នាក់រាជធានី ខេត្ត

354.968_PDP_PIP.2011
sh: Training

library.ncdd.gov.kh
015348

គ.ជ.អ.ប
NCDD

# វគ្គបណ្តុះបណ្តាលថ្នាក់រាជធានី ខេត្ត

គម្រោងសម្រាប់កិច្ចអភិវឌ្ឍសមត្ថភាព
ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ
នៅថ្នាក់រាជធានី ខេត្ត (PILAC2)

# មាតិកានៃឯកសារ

- **ផ្នែកទី១៖**
  - សេចក្តីណែនាំពីវគ្គបណ្តុះបណ្តាលថ្នាក់រាជធានី ខេត្ត
- **ផ្នែកទី២ ដល់ផ្នែកទី១០៖**
  - ដំណើរការ និងឧបករណ៍វិភាគលម្អិតសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត
- **ផ្នែកទី១១ ដល់ផ្នែកទី១៤៖**
  - ដំណើរការ និងឧបករណ៍វិភាគលម្អិតសម្រាប់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- **ផ្នែកទី១៥៖**
  - ការពិភាក្សាស្តីពីគោលការណ៍ទាំងប្រាំបួន (០៩) នៃ CPDP និង CPIP

1

គ.ជ.អ.ប
NCDD

JICA

# ផ្នែកទី ១

## សេចក្តីណែនាំពីវគ្គបណ្តុះបណ្តាល

គម្រោងសម្រាប់កិច្ចអភិវឌ្ឍសមត្ថភាព
ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ
នៅថ្នាក់រាជធានី ខេត្ត (PILAC2)

2

## គោលបំណង និងមាតិកា

គោលបំណងនៃផ្នែកទី ១៖

សិក្ខាកាមនឹងយល់ពីគោលបំណងនៃវគ្គបណ្តុះបណ្តាល និងចំណុចសំខាន់ៗនៃវគ្គបណ្តុះបណ្តាល។

មាតិកា៖
១. គោលបំណងនៃវគ្គបណ្តុះបណ្តាល
២. សារតានៃលិខិតបទដ្ឋានគតិយុត្ត
៣. វិន័យនៃវគ្គបណ្តុះបណ្តាល

3

# គោលបំណងនៃវគ្គបណ្តុះបណ្តាល

- អ្នកចូលរួមវគ្គបណ្តុះបណ្តាលអាចរៀបចំ ចាត់ចែងដំណើរការនៃការកសាង CPDP និង CPIP ។
- អ្នកចូលរួមវគ្គបណ្តុះបណ្តាលអាចពន្យល់ និងគាំទ្រដល់អ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីត្រៀមរៀបចំឯកសារចាំបាច់នានា និងតារាងក្នុង CPDP និង CPIP ។

***<u>ទម្រង់អក្សរកាត់សំខាន់ៗ</u>***

CPDP = ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត
CPIP = កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

4

# សិក្ខាកាមគោលដៅ

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- មន្ត្រីរាជធានី ខេត្តពាក់ព័ន្ធ ដែលគាំទ្រដល់ការកសាង CPDP និង CPIP

5

## លិខិតបទដ្ឋានគតិយុត្តសំខាន់ៗ

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (OL) ត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីខែឧសភា ឆ្នាំ២០០៨
- អនុក្រឹត្យស្តីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានប្រកាសឱ្យប្រើប្រាស់នៅខែធ្នូ ឆ្នាំ២០០៩ (អនុក្រឹត្យលេខ ២១៩ អនក្រ.បក)
- អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កាលពីខែធ្នូ ឆ្នាំ ២០១០ (អនុក្រឹត្យលេខ ១៥២ អនក្រ.បក)
- ប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កាលពីខែធ្នូ ឆ្នាំ២០១០ (ប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រក)

6

## ច្បាប់រៀបចំអង្គការ

- ច្បាប់នេះជាច្បាប់មូលដ្ឋានដើម្បីកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ
- ច្បាប់នេះកំណត់អាណត្តិរបស់ក្រុមប្រឹក្សាក្នុងការកសាង CPDP និង CPIP
- រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួនដែលត្រូវជ្រើសរើសតាមការបោះឆ្នោតអសកល
- ក្រុមប្រឹក្សា មានអាណត្តិ ០៥ឆ្នាំ។ (OL មាត្រា ១៥)

7

## ច្បាប់រៀបចំអង្គភាព (ត)

- ក្រុមប្រឹក្សា ត្រូវរៀបចំកសាងផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ តាមការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ។

8

## អនុក្រឹត្យលេខ ២១៩

- ប្រកាសឱ្យប្រើប្រាស់នៅខែធ្នូ ឆ្នាំ២០០៩
- កំណត់នីតិវិធីសម្រាប់ការកសាងផែនការ CPDP និង CPIP
- កំណត់អំពីការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនានា

9

## អនុក្រឹត្យលេខ ២១៩ (ត)

- ផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រើប្រាស់ធ្វើជាមូលដ្ឋានយុទ្ធសាស្ត្រសម្រាប់ណែនាំរាល់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការងារអភិវឌ្ឍ ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

10

## អនុក្រឹត្យលេខ ២១៩ (ត)

- ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខណ្ឌ សង្កាត់ ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរាជធានីភ្នំពេញ
- ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់សង្កាត់ក្នុងក្រុង ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ក្រុង

11

## អនុក្រឹត្យលេខ ១៥២

- ប្រកាសឲ្យប្រើ នៅខែធ្នូ ឆ្នាំ២០១០
- កែសម្រួលក្របខ័ណ្ឌពេលវេលាក្នុងការកសាង CPDP និង CPIP ដោយតម្រូវឲ្យក្រុមប្រឹក្សារាជធានី ខេត្ត ចាំបាច់ត្រូវកសាង CPDP និង CPIP ឱ្យបានយ៉ាងយូរ បំផុតក្នុងឆ្នាំទី២ នៃអាណត្តិក្រុមប្រឹក្សា

12

## ប្រកាសអន្តរក្រសួងលេខ ២៤១៧

- ប្រកាសឲ្យប្រើ នៅខែធ្នូ ឆ្នាំ២០១០
- កំណត់នីតិវិធីលម្អិតក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

13

# វិន័យនៃវគ្គបណ្តុះបណ្តាល

- ក្នុងអំឡុងពេលនៃសិក្ខាសាលារយៈពេលបួន (០៤) ថ្ងៃ សិក្ខាកាមត្រូវគោរពនូវវិន័យមួយចំនួនដូចខាងក្រោមៈ
  - សូមគោរពតាមពេលវេលា
  - សិក្ខាកាមទាំងអស់ គួរចូលរួមវគ្គបណ្តុះបណ្តាលឱ្យបានពេញលេញ
  - សូមបិទទូរស័ព្ទដៃ ឬសូមដាក់ទូរស័ព្ទរបស់អ្នកដោយសំលេងស្ងាត់ ដោយមិនមានសំលេងរោទិ៍
  - ធ្វើសំណួរសាកល្បងមុនវគ្គ និងក្រោយវគ្គបណ្តុះបណ្តាល

14

# សំណួរ និងចម្លើយ

- តើមានសំណួរទាក់ទងនឹងវគ្គបណ្តុះបណ្តាលឬទេ?

15

# សូមអរគុណ

16

# ផ្នែកទី ២

# ដំណើរការកសាងផែនការអភិវឌ្ឍន៍
# រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត

## ជំហានទី ១

គ.ជ.អ.ប
NCDD

JICA

# ផ្នែកទី ២

## ដំណើរការកសាងផែនការអភិវឌ្ឍន៍ រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត ជំហានទី ១

គម្រោងសម្រាប់កិច្ចអភិវឌ្ឍសមត្ថភាព
ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ
នៅថ្នាក់រាជធានី ខេត្ត (PILAC2)

# គោលបំណង និងមាតិកា

គោលបំណងនៃផ្នែកទី ២ ៖

សិក្ខាកាមនឹងយល់ពីដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត (CPDP) ជំហានទី ១

មាតិកា៖
១- សាវតា
២- លទ្ធផលនៃដំណើរការកសាងផែនការអភិវឌ្ឍន៍ ជំហានទី ១

1

## ទំនាក់ទំនងរវាងសេចក្តីណែនាំបច្ចេកទេស ឯកសារបណ្តុះបណ្តាល និងឯកសារបទបង្ហាញ

- សេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ រាជធានី ខេត្ត ជាឯកសារផ្លូវការ រៀបចំដោយក្រសួងផែនការ និង ក្រសួងមហាផ្ទៃ។
- ឯកសារបណ្តុះបណ្តាលស្តីពី CPDP ត្រូវបានរៀបចំដើម្បីជួយ អ្នកពាក់ព័ន្ធ ដែលទាក់ទងនឹងការកសាង CPDP ដោយផ្អែកលើ សេចក្តីណែនាំបច្ចេកទេសជាឯកសារយោង ។
- ឯកសារបទបង្ហាញរៀបចំឡើងដើម្បីបង្ហាញសិក្ខាកាម នូវចំណុច ជ្រើសរើសសំខាន់ៗមួយចំនួន ផ្អែកលើឯកសារបណ្តុះបណ្តាល ។

2

## គោលការណ៍ទាំងប្រាំបួន (០៩) នៃCPDP

- ការចែករំលែកព័ត៌មាន
- តម្លាភាព
- សង្គតិភាព និងសុខដុមនីយកម្ម
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ការឆ្លើយតបនឹងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធភាព និងសុក្រឹត្យភាពសេដ្ឋកិច្ច និងសង្គម
- ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
- ការធានាសមធម៌

3

# អ្នកពាក់ព័ន្ធសំខាន់ៗ នៃ CPDP

- ក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី ខេត្ត (TFC) និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា
- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ
- ទីចាត់ការនានានៃសាលារាជធានី ខេត្ត
- មន្ទីរ អង្គភាពនានាប្រចាំរាជធានី ខេត្ត
- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- ប្រជាពលរដ្ឋ
- អង្គការសង្គមស៊ីវិល និងវិស័យឯកជន

4

# តួនាទីរបស់អ្នកពាក់ព័ន្ធ

***តួនាទីរបស់ក្រុមប្រឹក្សារាជធានី ខេត្ត***

- ណែនាំផ្នែកគោលនយោបាយទូទៅសម្រាប់រៀបចំខ្លឹមសារផែនការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍
- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍន៍ក្នុងករណីចាំបាច់
- តាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំលើការអនុវត្តផែនការអភិវឌ្ឍន៍

5

# តួនាទីរបស់អ្នកពាក់ព័ន្ធ (ត)

*តួនាទីរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និង គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា*

- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- សម្របសម្រួលការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍
- ពិនិត្យ និងជូនយោបល់ទៅក្រុមប្រឹក្សា មុនធ្វើការអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍

6

# តួនាទីរបស់អ្នកពាក់ព័ន្ធ (ត)

***តួនាទីរបស់គណៈអភិបាលរាជធានី ខេត្ត***

- ដឹកនាំ និងសម្របសម្រួលការងារកសាងផែនការអភិវឌ្ឍន៍ ស្របតាមការណែនាំពីក្រុមប្រឹក្សាដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- ដឹកនាំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- ពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍មុនក្រុមប្រឹក្សាអនុម័ត
- ដាក់ជូនក្រុមប្រឹក្សា ពិនិត្យនិងអនុម័តផែនការអភិវឌ្ឍន៍
- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍

7

## តួនាទីរបស់អ្នកពាក់ព័ន្ធ (ត)

*តួនាទីរបស់ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ*

- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា
- រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍
- ដឹកនាំ និងសម្របសម្រួលដំណើរការកសាងផែនការអភិវឌ្ឍន៍
- រៀបចំសិក្ខាសាលា វេទិកាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានាក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍

8

## តួនាទីរបស់អ្នកពាក់ព័ន្ធ (ត)

*តួនាទីរបស់ទីចាត់ការនានានៃសាលារាជធានី ខេត្ត*

- ជួយក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្តក្នុងការដឹកនាំ និងសម្របសម្រួលដំណើរការកសាង អនុម័ត តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- សហការជាមួយក្រុមការងារកសាងផែនការរាជធានី ខេត្តក្នុងការដឹកនាំ និងសម្របសម្រួលការកសាង ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ចូលរួមក្នុងការវិភាគស្ថានភាពរាជធានី ខេត្ត
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

9

## តួនាទីរបស់អ្នកពាក់ព័ន្ធ (ត)

*តួនាទីរបស់មន្ទីរ អង្គភាពប្រចាំរាជធានី ខេត្ត*

- ចូលរួម និងផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍
- ចូលរួមក្នុងការវិភាគស្ថានភាពរាជធានី ខេត្ត
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

10

## តួនាទីរបស់អ្នកពាក់ព័ន្ធ (ត)

*តួនាទីរបស់ក្រុមប្រឹក្សាគ្រប់ក្រុង ស្រុក ខណ្ឌ*

- ចូលរួម និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

11

# តួនាទីរបស់អ្នកពាក់ព័ន្ធ (ត)

*តួនាទីរបស់ប្រជាពលរដ្ឋ*

- កំណត់បញ្ហា និងតម្រូវការអាទិភាពនានា តាមរយៈការចូលរួមក្នុងដំណើរការកសាងផែនការឃុំ សង្កាត់
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ចូលរួមក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍

12

# តួនាទីរបស់អ្នកពាក់ព័ន្ធ (ត)

*តួនាទីរបស់អង្គការសង្គមស៊ីវិល និងវិស័យឯកជន*

- ចូលរួម និងផ្តល់នូវព័ត៌មាននានាដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍
- ចូលរួមក្នុងការវិភាគស្ថានភាពរាជធានី ខេត្ត
- ចូលរួមក្នុងការពិភាក្សា និងពិគ្រោះយោបល់នានាដែលពាក់ព័ន្ធនឹងដំណើរការកសាងផែនការអភិវឌ្ឍន៍។

13

# ដំណើរការកសាង CPDP និង CPIP

- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត(CPDP)

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត → ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត → ជំហានទី៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត → ជំហានទី៤៖ ការអនុម័ត CPDP

- កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត(CPIP)

ជំហានទី១៖ ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់ CPIP → ជំហានទី២៖ ការរៀបចំសេចក្តីព្រាង CPIP → ជំហានទី៣៖ ការអនុម័ត CPIP

14

# នីតិវិធីកសាងផែនការ៖ ជំហានទី១

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

↓

ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

↓

ជំហានទី៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

↓

ជំហានទី៤៖ ការអនុម័ត ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

15

**ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

*គោលបំណង*

- រៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ប្រតិទិនការងារកសាងផែនការ ការណែនាំអំពីការបំពេញតារាងចាំបាច់នានា របស់ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា
- រៀបចំទិន្នន័យ និងឯកសារពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

16

**ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត(បន្ត)**

*លទ្ធផលរំពឹងទុក*

- គោលការណ៍ណែនាំផ្នែកគោលនយោបាយ ស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត អនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត
- ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ត្រូវបានរៀបចំ និងអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត
- តារាងបញ្ជីបូកសរុបបញ្ហា និងតម្រូវការនានារបស់ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា ត្រូវរៀបចំ (តារាង១.៥ តារាង១.៦ តារាង១.៧ និងតារាង១.៨)
- ឯកសារពាក់ព័ន្ធ នឹងត្រូវប្រើប្រាស់ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ រាជធានី ខេត្ត

17

### ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

១-១. កិច្ចប្រជុំណែនាំ

↓

១-២. ការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ

↓

១-៣. ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍

↓

១-៤. ការរៀបចំវឌ្ឍនភាពរបស់រាជធានី ខេត្តក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ សហស្សវត្សកម្ពុជា

↓

១-៥. ការរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា

18

### ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

១-១. កិច្ចប្រជុំណែនាំ

*គោលបំណង*

ដើម្បីផ្ដល់ការណែនាំស្ដីពីការបំពេញតារាងបញ្ហា និងតម្រូវការអាទិភាព

*សមាសភាព*

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត (PWG)
- តំណាងគណៈអភិបាលរាជធានី ខេត្ត (BOG)
- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត និងតំណាងគណៈកម្មាធិការពាក់ព័ន្ធនានា
- តំណាងគណៈអភិបាលក្រុង ស្រុក ខណ្ឌ
- តំណាងមន្ទីរ អង្គភាពក្នុងរាជធានី ខេត្ត
- តំណាងអង្គការសង្គមស៊ីវិលនានាក្នុងរាជធានី ខេត្ត
- តំណាងវិស័យឯកជនសំខាន់ៗ ក្នុងរាជធានី ខេត្ត
- អ្នកពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់ ។

19

**ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

## ១-១. កិច្ចប្រជុំណែនាំ (បន្ត)

*លទ្ធផល*

- ឯកសារបទបង្ហាញ,
- តារាង១.១ តារាង១.២ តារាង១.៣ និងតារាង១.៤

20

**ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត (ត)**

## ១-២. ការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ

គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា គឺជាឯកសារមូលដ្ឋានគន្លឹះ សម្រាប់ណែនាំ និងតម្រង់ទិសក្នុងការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងកម្មវិធីវិនិយោគរាជធានី ខេត្ត។ ឯកសារណែនាំផ្នែកគោលនយោបាយនេះ ត្រូវផ្អែកលើតម្រូវការមូលដ្ឋាន សក្តានុពលជាក់ស្តែង ដែលមានក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត និងឯកសារគោលនយោបាយថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ។

21

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត (ត)

## ១-៣. ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍

- ប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ គឺផែនកសកម្មភាព ដែលកំណត់អំពីសកម្មភាព ពេលវេលា ទីកន្លែង អ្នកទទួលខុសត្រូវ និងធនធានដែលត្រូវការចាំបាច់ (ដូចទម្រង់គំរូ)។

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត ត្រូវរៀបចំសេចក្តីព្រាងប្រតិទិនការងារនេះ ដើម្បីដាក់ជូនគណៈអភិបាល ពិនិត្យ និងផ្តល់យោបល់ មុននឹងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

22

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

## ១-៣. ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ (បន្ត)

| ល.រ | សកម្មភាព | ពេលវេលា | ទីកន្លែង | អ្នកទទួលខុសត្រូវ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|

ប្រតិទិនការងារកសាងផែនការខាងលើនេះ ត្រូវបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ______អនុម័តក្នុងកិច្ចប្រជុំ ______លើកទី_____នាថ្ងៃទី___ខែ_____ ឆ្នាំ______។

**ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត**

23

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

## ១-៤. ការរៀបចំវឌ្ឍនភាពរបស់រាជធានី ខេត្តក្នុងការអនុវត្ត គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា

ការិយាល័យផែនការរាជធានី ខេត្ត ដោយមានការជួយពីមន្ទីរផែនការរាជធានី ខេត្ត ត្រូវជួយរៀបចំឯកសារវឌ្ឍនភាពរបស់រាជធានី ខេត្តក្នុងការអនុវត្ត គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ដោយផ្អែកលើទិន្នន័យមូលដ្ឋានរាជធានី ខេត្ត ដោយធៀបនឹងចំណុចដៅ និងសូចនាករនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា និងផែនការយុទ្ធសាស្ត្រជាតិ ទៅតាមនីតិវិធីដែលបានរៀបចំដោយក្រសួងផែនការ។

24

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

## ១-៥. ការរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា

*គោលបំណង*

រៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា

*សមាសភាព*

- មន្ទីរ អង្គភាពរាជធានី ខេត្តពាក់ព័ន្ធ
- ក្រុមការងារកសាងផែនការ (PWG)

*លទ្ធផល*

ថតចម្លងឯកសារពាក់ព័ន្ធនានា និងបញ្ជីឯកសារនានា

25

# ឯកសារពាក់ព័ន្ធ CPDP

- ប្រកាស ឬគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាស្តី ពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត ដែលបានមកពីការច្នៃទិន្នន័យ មូលដ្ឋានឃុំ សង្កាត់
- សេចក្តីសង្ខេបព័ត៌មានស្ថានភាពរាជធានី ខេត្តតាមផ្នែកនីមួយៗ (ទម្រង់ គំរូ)
- ឯកសារវឌ្ឍនភាពនៃការកាត់បន្ថយភាពក្រីក្រ ក្នុងការអនុវត្តគោលដៅ អភិវឌ្ឍន៍សហវត្សរ៍ថ្នាក់មូលដ្ឋាន (ផ្តល់ដោយមន្ទីរផែនការរាជធានីខេត្ត)
- ឯកសារព័ត៌មានពីដៃគូអភិវឌ្ឍន៍នានា ដែលមានសកម្មភាពក្នុងរាជធានី ខេត្ត

26

# ឯកសារពាក់ព័ន្ធ CPDP(ត)

- បណ្តាផែនទីធំៗ ( ទំហំ A0 ឬ A1 ) (ប្រើប្រាស់ក្នុងកិច្ចប្រជុំកសាង ផែនការ) ដូចជា៖
  - ផែនទីភូមិសាស្ត្ររដ្ឋបាលបង្ហាញពីព្រំប្រទល់  ឬដង់ស៊ីតេ ប្រជាជន ការប្រើប្រាស់ដីធ្លី និងហេដ្ឋារចនាសម្ព័ន្ធសង្គមសំខាន់ៗ
- ឯកសារផែនការអភិវឌ្ឍន៍ពីមុនរបស់រាជធានី ខេត្ត ( បើមាន)
- ផែនការអភិវឌ្ឍរបស់វិស័យ និង ឬ ថ្នាក់គ្រប់គ្រងរដ្ឋបាលពាក់ព័ន្ធនានា
- ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- តារាងម៉ាទ្រិចសកម្មភាពអាទិភាពរបស់រាជធានី ខេត្ត (យកតាមកាលបរិច្ឆេទចុងក្រោយ)
- តារាងបញ្ហា និងតម្រូវការសំខាន់ៗមួយចំនួនដូចខាងក្រោម៖
  - តារាង ១.១/ ១.២/ ១.៣/ ១.៤/ ១.៥/ ១.៦/ ១.៧/ ១.៨

27

សូមអរគុណ !

28

# <u>ផ្នែកទី ៣</u>

# ដើមឈើបញ្ហា និង

# ដើមឈើដំណោះស្រាយ

គ.ជ.អ.ប
NCDD

# ផ្នែកទី ៣

# ដើមឈើបញ្ហា និង ដើមឈើដំណោះស្រាយ

គម្រោងសម្រាប់កិច្ចអភិវឌ្ឍសមត្ថភាព
ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ
នៅថ្នាក់រាជធានី ខេត្ត (PILAC 2)




ដើមឈើបញ្ហា

# ដើមឈើបញ្ហា

**ដើមឈើបញ្ហា៖** ជាឧបករណ៍សម្រាប់វិភាគស្ថានភាព ដោយផ្តោតលើ បញ្ហា មូលហេតុនៃបញ្ហា និងឥទ្ធិពលដែលកើតចេញពីបញ្ហានោះ

**គោលបំណង៖** ដើម្បីកំណត់ពីបញ្ហាស្នូល មូលហេតុ និងឥទ្ធិពលដែលនឹងក្លាយជាមូលដ្ឋានក្នុងការរៀបចំចេញជា *គម្រោង* ដើម្បីដោះស្រាយបញ្ហាស្នូលនោះ

**ផ្នែកទាំងបីនៃដើមឈើបញ្ហា៖** ដើម(បញ្ហាស្នូល) ឫស(មូលហេតុ) និងមែកធាង(ឥទ្ធិពល)

3

# ការកំណត់បញ្ហាស្នូល

បញ្ហាស្នូល គឺជាចំណុចផ្តើមនៃការវិភាគដើមឈើបញ្ហា

→ ទំហំនៃការវិភាគ គឺអាស្រ័យទៅលើការកំណត់ បញ្ហាស្នូល



4

# តើត្រូវធ្វើដូចម្តេច ដើម្បីបង្កើត ដើមឈើបញ្ហា?

5

## ជំហានសំខាន់ៗសម្រាប់បង្កើតដើមឈើបញ្ហា

1. ពិចារណាអំពី *បញ្ហា* ដែលអាចមាន ដោយផ្អែកលើស្ថានភាពជាក់ស្តែង
2. កំណត់រក *បញ្ហាស្នូល* ដែលជាបញ្ហាចម្បងសម្រាប់ធ្វើការវិភាគ (ការពិនិត្យមើលនូវទំនាក់ទំនងនៃបញ្ហានានាដែលរកឃើញនៅចំណុចទី1 ខាងលើ អាចជួយឲ្យយើងរកឃើញនូវ បញ្ហាស្នូល នេះ)
3. កំណត់ថា បញ្ហាណាខ្លះជា មូលហេតុ ហើយ បញ្ហាណាខ្លះជា ឥទ្ធិពល។ បញ្ហាណាជាមូលហេតុ ត្រូវដាក់នៅខាងក្រោម បញ្ហាស្នូល ហើយបញ្ហាណាជាឥទ្ធិពល ត្រូវដាក់នៅខាងលើ បញ្ហាស្នូល

6

## ជំហានសំខាន់ៗសម្រាប់បង្កើតដើមឈើបញ្ហា

4. បន្តពិចារណារៀបចំជាទំនាក់ទំនងឋានានុក្រមនៃ មូលហេតុ និង ឥទ្ធិពល ខាងលើ(បញ្ហាណា ជាហេតុដែលនាំឲ្យមាន បញ្ហាមួយទៀត ត្រូវដាក់បញ្ហាជាហេតុនោះ នៅខាងក្រោម)៖
   - បើបញ្ហា *ក* គឺជាហេតុដែលនាំឲ្យមានបញ្ហា *ខ* នោះបញ្ហា *ក* ត្រូវនៅពីក្រោមបញ្ហា *ខ*




   - បើបញ្ហា *គ* គឺជាផលដែលកើតចេញពីបញ្ហា *ខ* នោះបញ្ហា *គ* ត្រូវនៅពីលើបញ្ហា *ខ*




7

## ជំហានសំខាន់ៗសម្រាប់បង្កើតដើមឈើបញ្ហា

5. គូសបន្ទាត់ភ្ជាប់បញ្ហាទាំងនោះ ដើម្បីបង្កើតជា ដើមឈើបញ្ហា (ត្រូវពិចារណារក មូលហេតុ - ឥទ្ធិពល បន្តទៀត បើចាំបាច់)




8

## ជំហានសំខាន់ៗសម្រាប់បង្កើតដើមឈើបញ្ហា

6. ពិចារណាលើបញ្ហានីមួយៗ ដើម្បីកំណត់រកមើលបញ្ហាយេនឌ័រ ដែលអាចត្រូវបានមើលរំលង

ឧទាហរណ៍៖ ការមិនមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់

→ បញ្ហាយេនឌ័រដែលមើលរំលង៖ ស្ត្រីត្រូវទទួលបន្ទុកក្នុងការដងទឹក សម្រាប់ប្រើប្រាស់

→ បន្ទាប់ពីបង្កើតដើមឈើបញ្ហាហើយ ត្រូវបំលែងដើមឈើបញ្ហានោះទៅជា **ដើមឈើដំណោះស្រាយ**

9

# តើត្រូវធ្វើដូចម្តេច ដើម្បីបង្កើត ដើមឈើដំណោះស្រាយ?

10

## ជំហានសំខាន់ៗសម្រាប់បង្កើតដើមឈើដំណោះស្រាយ

1. កែសម្រួលឃ្លា បញ្ហាស្នូល ទៅជា គោលដៅ ដោយការប្តូរឃ្លាបញ្ហាពីមុន ទៅជាស្ថានភាពជាវិជ្ជមាន ដែលក្នុងនោះ បញ្ហាស្នូល ត្រូវបានដោះស្រាយ
2. កែសម្រួលឃ្លា មូលហេតុផ្ទាល់ ទៅជា គោលបំណង តាមវិធីដូចខាងលើ
3. កែសម្រួលឃ្លា មូលហេតុរង ទៅជា គោលបំណងរង តាមវិធីដូចខាងលើ

11

## ដើមឈើដំណោះស្រាយ




12

## កំណត់សម្គាល់

ត្រូវធ្វើការប្រុងប្រយ័ត្ននូវចំណុចមួយចំនួនដូចខាងក្រោម៖

- បញ្ហា គឺជា ឃ្លាដែលមានន័យអវិជ្ជមាន
- ដំណោះស្រាយ គឺជា ឃ្លាដែលមានន័យវិជ្ជមាន
- ហេតុ និង ផល ត្រូវសរសេរដាច់ដោយឡែកពីគ្នា
- បញ្ហា ត្រូវសរសេរតែបញ្ហាណាដែលមានជាក់ស្តែង
- ដំណោះស្រាយ ត្រូវតែជា ដំណោះស្រាយ ដែលអាចអនុវត្តបាន
- ត្រូវសរសេរ ឃ្លា ឲ្យមានលក្ខណៈត្រឹមត្រូវ និងច្បាស់លាស់
- បញ្ហាណាដែលមិនអាចដោះស្រាយបាន ត្រូវដកទុកដោយឡែក

13

## កំណត់សម្គាល់ (ត)

- ចៀសវាងសរសេរ ឃ្លាថា "អត់មានរបស់នេះ ឬរបស់នោះ"

→ត្រូវសរសេរ ដោយគិតពីលទ្ធផលដែលកើតចេញពី ការអត់មាន របស់នោះ

ឧទាហរណ៍

| មិនល្អ | | ល្អ |
|---|---|---|
| គ្មានមន្ទីរពេទ្យ | → | ប្រជាពលរដ្ឋមិនអាចទទួលសេវាសុខភាពបានគ្រប់គ្រាន់ |

14

## ករណីសិក្សា (១)

ប្រជាពលរដ្ឋនៅក្នុងភូមិមួយបានឲ្យដឹងថា រយៈពេល១ខែមកហើយ ដែលសត្វពាហនៈរបស់ពួកគាត់បានរងនូវជំងឺអុតក្តាមចម្លែកមួយ ដែលធ្វើឲ្យសត្វទាំងនោះងាប់ក្នុងរយៈពេលពី ៤ ទៅ ៥ថ្ងៃ បើទោះបីជាមានការជួយសង្គ្រោះពីសំណាក់ពួកគាត់យ៉ាងណាក្តី ជាពិសេសគ្រួសារដែលមានស្ត្រីជាមេគ្រួសារ។

ដោយឃើញសភាពបែបនេះ ពួកគាត់ក៏បានរាយការណ៍ជូនទៅលោកមេឃុំ ប៉ុន្តែពុំបានទទួលផលអ្វីជាដុំកំភួនឡើយ ក្រៅពីការជួយសង្គ្រោះពីសំណាក់មន្ត្រីបសុពេទ្យដែលមានភាពយឺតយ៉ាវ និងធកល្វែងជាទីបំផុត។ ដោយសារពុំមានលុយបង់ អ្នកភូមិមិនអាចហៅពេទ្យសត្វមកចាក់ថ្នាំបានទេ ជាហេតុធ្វើឲ្យគាត់បង្ខំលក់សត្វឈឺទាំងនោះ ទៅឲ្យអ្នកកាប់សាច់លក់ (រួចបញ្ជូនទៅទីសត្តឃាត)។

15

## ករណីសិក្សា (១)

ប្រជាពលរដ្ឋជាស្ត្រីម្នាក់នៅក្នុងភូមិ បានឲ្យដឹងថា ពួកគាត់នឹងខ្វះកម្លាំងសម្រាប់អូសទាញនារដូវបង្កបង្កើនផលឆ្នាំក្រោយ។

លោកមេឃុំបានលើកឡើងថា គាត់បានរាយការណ៍ទៅខាងស្រុក និងបានដុតសត្វដែលងាប់ដោយសារជំងឺនោះខ្លះដែរ ប៉ុន្តែមិនបានទាំងអស់នោះទេ។ ព្រមជាមួយនេះ លោកប្រធានមន្ទីរជំនាញខេត្តក៏បានឲ្យដឹងផងដែរថា ចំពោះករណីនេះ ខាងមន្ទីរបានចាត់ឲ្យមន្ត្រីពេទ្យសត្វចុះទៅមូលដ្ឋានហើយ តែបើចង់ដឹងច្បាស់សូមសួរទៅខាងពេទ្យសត្វទើបដឹងរឿងកាន់តែច្បាស់។

16

## ការវិភាគលើករណីសិក្សា

### ១. កំណត់អំពីបញ្ហានានាដែលកើតមាន

- សត្វពាហនៈនៅក្នុង
ភូមិមានជំងឺអុតក្តាម
ចម្លែករហូតងាប់
- ប្រជាពលរដ្ឋខ្វះ
ចំណេះដឹងអំពីជំងឺ
អុតក្តាម
- ការឆ្លើយតបរបស់មេឃុំ
មិនទាន់ពេលវេលា
- មន្ត្រីបសុពេទ្យផ្តល់
សេវាមិនបានល្អ
- ប្រជាពលរដ្ឋខ្វះថវិកា
សម្រាប់អញ្ជើញពេទ្យ
សត្វមកព្យាបាល
- ប្រជាពលរដ្ឋមិនអាច
អញ្ជើញពេទ្យសត្វបាន
- មន្ទីរជំនាញខេត្តខ្វះ
ទំនួលខុសត្រូវ
- ប្រជាពលរដ្ឋត្រូវបង្ខំ
ចិត្តលក់សត្វឈឺ
- ប្រជាពលរដ្ឋខ្វះកម្លាំង
អូសទាញសម្រាប់ឆ្នាំ
ក្រោយ

17

## ការវិភាគលើករណីសិក្សា

### ២. កំណត់រកបញ្ហាស្នូល

- សត្វពាហនៈនៅក្នុង
ភូមិមានជំងឺអុតក្តាម
ចម្លែករហូតងាប់
- ប្រជាពលរដ្ឋខ្វះ
ចំណេះដឹងអំពីជំងឺ
អុតក្តាម
- ការឆ្លើយតបរបស់មេឃុំ
មិនទាន់ពេលវេលា
- មន្ត្រីបសុពេទ្យផ្តល់
សេវាមិនបានល្អ
- ប្រជាពលរដ្ឋខ្វះថវិកា
សម្រាប់អញ្ជើញពេទ្យ
សត្វមកព្យាបាល
- ប្រជាពលរដ្ឋមិនអាច
អញ្ជើញពេទ្យសត្វបាន
- មន្ទីរជំនាញខេត្តខ្វះ
ទំនួលខុសត្រូវ
- ប្រជាពលរដ្ឋត្រូវបង្ខំ
ចិត្តលក់សត្វឈឺ
- ប្រជាពលរដ្ឋខ្វះកម្លាំង
អូសទាញសម្រាប់ឆ្នាំ
ក្រោយ

18

## ការវិភាគលើករណីសិក្សា

### ២. កំណត់រកបញ្ហាស្នូល (ត)

ប្រជាពលរដ្ឋខ្វះកម្លាំងអូសទាញសម្រាប់ឆ្នាំក្រោយ

ប្រជាពលរដ្ឋត្រូវបង្ខំចិត្តលក់សត្វឈឺ

សត្វពាហនៈនៅក្នុងភូមិមានជំងឺអុតក្តាមចម្លែករហូតងាប់

ប្រជាពលរដ្ឋខ្វះចំណេះដឹងអំពីជំងឺអុតក្តាម

ការឆ្លើយតបរបស់មេឃុំមិនទាន់ពេលវេលា

មន្ត្រីបសុពេទ្យផ្តល់សេវាមិនបានល្អ

ប្រជាពលរដ្ឋខ្វះថវិកាសម្រាប់អញ្ជើញពេទ្យសត្វមកព្យាបាល

ប្រជាពលរដ្ឋមិនអាចអញ្ជើញពេទ្យសត្វបាន

មន្ទីរជំនាញខេត្តខ្វះទំនួលខុសត្រូវ

19

## ការវិភាគលើករណីសិក្សា

### ៣. បង្កើតជាដើមឈើបញ្ហា




20


ការវិភាគលើករណីសិក្សា
៣. កំណាត់រកបញ្ហាឈើនឌុំរ
ប្រជាពលរដ្ឋខ្វះកម្លាំងអូសទាញសម្រាប់ឆ្នាំក្រោយ
ប្រជាពលរដ្ឋត្រូវបង្ខំចិត្តលក់សត្វឈើ
សត្វពាហនៈនៅក្នុងភូមិមានជំងឺអុតក្តាមចម្លែករហូតងាប់
ស្ត្រីហាក់មានឱកាសតិចក្នុងការទទួលព័ត៌មានអំពីជំងឺសត្វ
ប្រជាពលរដ្ឋខ្វះចំណេះដឹងអំពីជំងឺអុតក្តាម
ការឆ្លើយតបរបស់ឃុំមិនទាន់ពេលវេលា
មន្ត្រីបសុពេទ្យផ្តល់សេវាមិនបានល្អ
ប្រជាពលរដ្ឋមិនអាចអញ្ជើញពេទ្យសត្វបាន
ពុំមានការផ្សព្វផ្សាយអំពីជំងឺសត្វ
សមត្ថភាពរដ្ឋបាលឃុំមានកំរិត
មន្ទីរជំនាញខេត្តខ្វះទំនួលខុសត្រូវ
ប្រជាពលរដ្ឋខ្វះថវិកាសម្រាប់អញ្ជើញពេទ្យសត្វមកព្យាបាល
21


ការវិភាគលើករណីសិក្សា
៤. បំលែងជាដើមឈើដំណោះស្រាយ
ប្រជាពលរដ្ឋមានកម្លាំងអូសទាញ
ប្រជាពលរដ្ឋមិនបង្ខំចិត្តលក់សត្វ
សត្វពាហនៈនៅក្នុងភូមិមានសុខភាពល្អ
ស្ត្រីមានឱកាសស្មើគ្នាក្នុងការទទួលព័ត៌មានអំពីជំងឺសត្វ
ប្រជាពលរដ្ឋមានចំណេះដឹងអំពីជំងឺសត្វ
ការឆ្លើយតបរបស់មេឃុំទាន់ពេលវេលា
សេវារបស់មន្ត្រីបសុពេទ្យត្រូវបានកែលម្អ
ប្រជាពលរដ្ឋអាចទទួលបានសេវាបសុពេទ្យ
ផ្សព្វផ្សាយអំពីជំងឺសត្វដល់ប្រជាពលរដ្ឋ
បណ្តុះបណ្តាលឃុំអំពីអភិបាលកិច្ចល្អ
ពង្រឹងរបៀបរបបការងាររបស់មន្ទីរ
បង្កើតពេទ្យសត្វសហគមន៍សម្រាប់ប្រជាពលរដ្ឋ
22

## លទ្ធផលវិភាគ ត្រូវបានប្រើប្រាស់ដើម្បីបញ្ចូលទៅក្នុង តារាង ១.១ ដល់ ១.៤

| ការវិភាគដើមឈើបញ្ហា/ដើមឈើដំណោះស្រាយ | តារាង១.១ ដល់តារាង១.៤ |
|---|---|
| បញ្ហាស្នូល | បញ្ហា |
| មូលហេតុផ្ទាល់ | មូលហេតុ |
| មូលហេតុរង | ------------------------------- |
| គោលដៅ | សកម្មភាព ឬសេវា |
| គោលបំណង | ------------------------------- |
| គោលបំណងរង | ដំណោះស្រាយ |

23

## លំហាត់

១) សិក្ខាកាមត្រូវបែងចែកជា ២ក្រុម
២) ស្នើឲ្យសិក្ខាកាមអានន្ទូវករណីសិក្សាដែលបានចែកជូន
៣) ជាដំបូង ពិភាក្សា និងពិនិត្យលើបញ្ហាស្នូល
៤) កសាងបញ្ហាដើមឈើ
- ដើម្បីបំពេញតារាងនៃផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត សូមរកបញ្ហាឲ្យដល់មូលហេតុរង។

៥) កសាងដើមឈើដំណោះស្រាយ

(១ម៉ោង ៤០នាទី)

24

សូមអរគុណ!

# ផ្នែកទី ៣:

# ករណីសិក្សា: បញ្ហាផ្គត់ផ្គង់ទឹក

## [ព័ត៌មានទូទៅ]

លក្ខណៈទូទៅនៃទីក្រុងបាអាន

ទីក្រុងបាអាន គឺជារាជធានីនៃប្រទេសក ដែលស្ថិតនៅភាគឦសាននៃប្រទេស។

ផ្ទៃក្រឡា : ប្រហែល ៧៩០ គីឡូម៉ែតការ៉េ ($km^2$)

ចំនួនប្រជាជន : ប្រហែល ៦លាននាក់

## [ប្រព័ន្ធផ្គត់ផ្គង់ទឹកនៅក្នុងទីក្រុងបាអាន និងស្ថានភាពបច្ចុប្បន្ន]

### ១. ប្រព័ន្ធផ្គត់ផ្គង់ទឹក (តំបន់គ្របដណ្តប់ដោយក្រុមហ៊ុន BWSC) នៅក្នុងទីក្រុងបាអាន

ប្រព័ន្ធផ្គត់ផ្គង់ទឹកសាធារណៈ: ត្រូវបានដំណើរការនិងគ្រប់គ្រងដោយក្រុមហ៊ុន BWSC នៅក្នុងទីក្រុង បាអាន។ សេចក្តីលម្អិតនៃប្រព័ន្ធផ្គត់ផ្គង់ទឹក និងការរៀបចំចាត់ចែងរបស់ BWSC មានបង្ហាញដូចខាងក្រោម។

១-១. <u>បណ្តាញចែកចាយទី១ រោងចក្របន្សុទ្ធទឹក និងប្រភពទឹក</u>

៧៥%នៃទឹកស្អាតត្រូវបានចែកចាយនៅក្នុងតំបន់សេវារបស់ក្រុមហ៊ុន BWSC តាមរយៈបណ្តាញចែកចាយទី១។ តំបន់នេះភាគច្រើនជាតំបន់ប្រជុំជន និងតំបន់ពាណិជ្ជកម្ម។ ទឹកត្រូវបានបន្សុទ្ធ នៅរោងចក្របន្សុទ្ធទឹកចំនួន២នៅក្នុងទីក្រុងបាអាន។ ប្រភពទឹក គឺទន្លេចៅ។ ទន្លេនេះគឺមិនដែលរីងស្ងួតទេ ប៉ុន្តែកម្រិតទឹកធ្លាក់ចុះខ្លាំងនៅក្នុងរដូវប្រាំង។

- **រោងចក្របន្សុទ្ធទឹក ក:**

បានសាងសង់២ឆ្នាំមុន និងមានដំណើរការពេញលេញ។ ថវិកាភាគច្រើនសម្រាប់ការទិញសារធាតុគីមី និងគ្រឿងបន្លាស់ គឺពឹងផ្អែកទៅលើការគាំទ្រផ្នែកហិរញ្ញវត្ថុពីម្ចាស់ជំនួយ។

- **រោងចក្របន្សុទ្ធទឹក ខ:**

រោងចក្រនេះចាស់ ហើយដំណើរការមិនសូវល្អ។ រោងចក្រនេះអាចផ្តល់បានត្រឹមតែ ៦០%នៃសមត្ថភាពដើមរបស់វាតែប៉ុណ្ណោះ។ សម្ភារៈបរិក្ខាមួយចំនួនត្រូវបានខូចខាត ពីព្រោះសម្ភារៈបរិក្ខារទាំងនេះកម្រធ្វើការសាកល្បង ឬថែទាំជាប្រចាំ។ ជាញឹកញាប់សារធាតុគីមីបន្សុទ្ធទឹកបានអស់ ដោយសារក្រុមហ៊ុន BWSC ខ្វះថវិការ ។

## ១-២. បណ្តាញចែកចាយទី២ ស្ថានីយ៍បូមទឹក និងប្រភពទឹក

ទឹក២៥% នៃតំបន់ផ្តល់សេវារបស់ក្រុមហ៊ុន BWSC ត្រូវឆ្លងកាត់បណ្តាញចែកចាយទី២។ តំបន់នេះ រួមមានទីក្រុងចាស់ និងតំបន់ប្រជាជនដែលមានចំណូលទាបរស់នៅ។ ទឹកត្រូវបានផ្គត់ផ្គង់ពីស្ថានីយ៍បូមទឹកទាំង៥ ដែលដាក់ពង្រាយជុំវិញទីក្រុង។ ស្ថានីយ៍បូមទឹកនីមួយៗ មានអណ្តូងជ្រៅផ្ទាល់ខ្លួនសម្រាប់ធ្វើជាប្រភពទឹក។ ប្រព័ន្ធនេះសមត្ថភាពនៅមានកម្រិត ពីព្រោះវាចាស់ណាស់ទៅហើយ (ដែលបានសាងសង់តាំងពីសម័យអាណានិគមមកម្ល៉េះ)។

## ២. **កំណត់បញ្ហានានា**

## ២-១. ចំនួនទឹកផ្គត់ផ្គង់ដោយបណ្តាញចែកចាយរបស់ក្រុមហ៊ុន BWSC គឺនៅមិនទាន់គ្រប់គ្រាន់

**អត្រាជ្រាបទឹក ត្រូវបានប៉ាន់ស្មានខ្ពស់ជាង ៥០%**

– បំពង់ចែកចាយមានសភាពចាស់ទ្រុតទ្រោម
– អ្នកបច្ចេកទេសមានសមត្ថភាពនៅមានកម្រិត ដើម្បីស្វែងរក និងជួសជុលកន្លែងជ្រាបទឹក
– ការលើកទឹកចិត្តចំពោះអ្នកបច្ចេកទេសនៅមានកម្រិតទាប

## ២-២. នៅទីក្រុងបាអាន ទឹកត្រូវបានគេលួចប្រើ

– ការខូចគ្រឿងបំណែកណាមួយ (បំពង់ និងនាឡិកាសម្រាប់វាស់) មិនត្រូវបានជួសជុល
– ប្រជាជនមានសីលធម៌ទាប
– ការពេញចិត្តទៅលើសេវារបស់ក្រុមហ៊ុន BWSC មានកម្រិតទាប

- **ករណីទី១: ការដោះនាឡិកាវាស់ទឹកចេញ**

  ជាញឹកញាប់ប្រជាជនក្នុងមូលដ្ឋាន ដោះនាឡិកាវាស់ទឹកធំដែលបំពាក់នៅលើផ្លូវចេញ។ ពួកគាត់ដងទឹកពេញៗធុង។ ក្រុមហ៊ុន BWSC អាចប្តឹងចំពោះបុគ្គលដែលដោះនាឡិកាទឹកចេញ ប្រសិនជាអាចរកឃើញបុគ្គលនោះ។ វិធីសាស្ត្រនេះមិនបានជួយបញ្ឈប់អ្នកដែលលួចទឹកបន្ទាប់ពីបានដោះនាឡិកាទឹកចេញទាំងនោះទេ។

- **ករណីទី២: ការបំពាក់ទុយយ៉ូទឹក**

  ប្រជាជនមួយចំនួនក្នុងចំណោមពួកគាត់ ភ្ជាប់ទុយយ៉ូទឹកនៅកន្លែងដំណរដែលខូច ដើម្បីតទៅផ្ទះរបស់ពួកគាត់តែម្តង។ ទម្រង់នៃការលួចបែបនេះកាន់តែមើលឃើញច្បាស់ឡើង ប៉ុន្តែពិបាកក្នុងការគ្រប់គ្រង។

## ២-៣. ទឹកដែលបានចែកចាយតាមបណ្តាញដែលមិនសមរម្យសម្រាប់បរិភោគ

ទឹកដែលចេញមិនទៀងទាត់ និងមានសម្ពាធទាប បណ្តាលឲ្យទឹកដែលចែកចាយមានគុណភាពអន់។ ទឹកដែលមានសម្ពាធទាប និងចេញមិនទៀងទាត់ គឺបណ្តាលមកពីការជ្រាប ការលួច និងការខូចខាតនូវសមត្ថភាពនៃបំពង់ចែកចាយ។

## ២-៤. បញ្ហាគ្រប់គ្រង និងរៀបចំ ចាត់ចែងរបស់ក្រុមហ៊ុន BWSC

កម្មករជាច្រើន ត្រូវបានការពារពីការកាត់បន្ថយបុគ្គលិក ហើយក្រុមហ៊ុន BWSC ទទួលរងសម្ពាធពីក្រសួង។ រដ្ឋាភិបាលបារម្ភថា ការបាត់បង់ការងារ មានន័យថាអ្នកគ្មានការងារមានកម្រិតខ្ពស់។ អ្នកគ្មានការងារធ្វើ អាចបណ្តាលឲ្យមានកុប្បកម្ម និងការបះបោរខាងនយោបាយ។

**អតីតនាយកប្រតិបត្តិរបស់ក្រុមហ៊ុន BWSC ដែលបច្ចុប្បន្ននេះបំរើការងារឲ្យក្រុមហ៊ុនឯកជនមួយបានបង្ហាញនូវទស្សនៈផ្សេងមួយថា:**

"វាជាការពិតណាស់ ប្រសិនបើពួកគេអាចបញ្ឈប់ការជ្រាបទឹកនិងការលួចទឹកបាន BWSC នឹងក្លាយជាក្រុមហ៊ុនដ៏ល្អមួយ។ ប៉ុន្តែខ្ញុំពុំគិតថា វាអាចធ្វើទៅរួចទេ។ ក្រុមហ៊ុននេះគ្មានវគ្គបណ្តុះបណ្តាលសម្រាប់អ្នកបច្ចេកទេស និងមិនមានអ្នកប្រមូលលុយគ្រប់គ្រាន់។ វាគួរឲ្យអស់សំណើចណាស់។ ក្រុមហ៊ុនមានបុគ្គលិកចំនួន ៩០០នាក់ ប៉ុន្តែក្រុមហ៊ុនមិនមានអ្នកប្រមូលលុយគ្រប់គ្រាន់ ហើយក្រុមហ៊ុនមិនមានអ្នកបច្ចេកទេសល្អ និងមិនមានអ្វីអាចធ្វើបានទេ។ យ៉ាងណាក៏ដោយ លុយដែលក្រុមហ៊ុនរកបានភាគច្រើន គឺចំណាយទៅលើប្រាក់ខែ និងឧបករណ៍គ្រឿងម៉ាស៊ីន ។ ក្រុមហ៊ុនត្រូវកាត់បន្ថយចំនួនបុគ្គលិក ប៉ុន្តែខ្ញុំដឹងថា ក្រុមហ៊ុនមិនអាចធ្វើបានទេ។ ក្រុមហ៊ុនមិនអាចធ្វើអ្វីដែលក្រសួងមិនជំទាស់នោះទេ។ តើការគ្រប់គ្រងនៅកន្លែងណា? ក្រុមហ៊ុននេះត្រូវការការកែទម្រង់ជាមូលដ្ឋាន។ មិនមែនសម្ភារៈបរិក្ខាទេ ប៉ុន្តែក្រុមហ៊ុនតែម្តង។"

**អ្នកប្រើប្រាស់ទឹកម្នាក់បានផ្តល់នូវទស្សនៈមួយផ្សេងទៀត:**

"យើងត្រូវការទឹកដែលមានសុវត្ថិភាព។ ប៉ុន្តែពួកគេមិនបានធ្វើអ្វីសោះ។ កូនស្រីរបស់ខ្ញុំមានជម្ងឺរាគតាំងពីសប្តាហ៍មុន។ គុណភាពទឹកប្រាកដជាមិនល្អ។ ហេតុអីខ្ញុំត្រូវបង់លុយឲ្យសម្រាប់ការប្រើទឹកគុណភាពអន់បែបនេះ? ប្រជាជនលួចទឹក ដោយសារក្រុមហ៊ុន BWSC មិនបានផ្តល់ទឹកស្អាតដល់ពួកយើង។ យើងត្រូវការទឹកស្អាត និងអាចជឿទុកចិត្តបាន។ ប្រសិនបើអ្នកអាចធានានូវទឹកដែលមានសុវត្ថិភាព ខ្ញុំនឹងបង់លុយឲ្យសម្រាប់ការប្រើប្រាស់ទឹក។ ឬ ប្រសិនបើអ្នកប្រាប់ខ្ញុំថាធ្វើយ៉ាងម៉េចដើម្បីទទួលបានទឹកដែលមានសុវត្ថិភាព ខ្ញុំនឹងមិត្តភក្តិរបស់ខ្ញុំ នឹងអនុវត្តតាម។ ហេតុអ្វីបានជាអ្នកមិនជួយយើង?"

ខាងលើនេះគឺជាលទ្ធផលនៃការសិក្សាបឋម ដែលបានអនុវត្តដោយក្រុមរៀបចំគម្រោង។ បច្ចុប្បន្ននេះតាមរយៈសិក្ខាសាលាផែនការគ្រប់គ្រងវដ្តគម្រោង សូមពិភាក្សា និងវិភាគពីលក្ខខណ្ឌ និងបញ្ហាព្រួយបារម្ភនានាអំពីការផ្គត់ផ្គង់ទឹកនៅក្រុងបាអាន។

## ផ្នែកទី៣:

# ករណីសិក្សា: ការលើកកម្ពស់សុខភាពស្ត្រី

**[ព័ត៌មានទូទៅ]**

ប្រទេស ក ស្ថិតនៅក្នុងតំបន់ឥណ្ឌូចិន ដែលបានកែលម្អសេវាសុខភាពមាតា និងកុមារ និងសេវាព្យាបាលជាអទិភាពក្នុងការអភិវឌ្ឍជាតិ។ អត្រាមរណៈភាពមាតានៅក្នុងខេត្ត ខ ខ្ពស់ជាងអត្រាជាមធ្យមនៅថ្នាក់ជាតិ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ។

ខេត្ត ខ គឺជាខេត្តមួយនៅក្នុងចំណោមខេត្តដែលក្រីក្របំផុតនៃប្រទេស ក ដោយហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗទ្រុតទ្រោម។ លើសពីនេះទៀត បុគ្គលិកថែទាំសុខភាពមានចំនួនតិច។ ការអង្កេតមួយបានធ្វើឡើងនៅក្នុងស្រុក ខ ហើយស្រុកនេះត្រូវបានគេចាត់ទុកថាជាលក្ខខណ្ឌទូទៅនៅក្នុងខេត្ត ខ។

### ១. សេវាសុខាភិបាលនៅក្នុងស្រុក ខ

ស្ថាប័នព្យាបាលសុខភាពនៅក្នុងស្រុក ខ ខាងក្រោម ផ្តល់សេវាសុខភាពមាតា និងកុមារ។

#### ១-១. <u>មន្ទីរពេទ្យស្រុក</u>

មន្ទីរពេទ្យស្រុក គឺជាមន្ទីរពេទ្យព្យាបាលជម្ងឺទូទៅដែលមានទំហំមធ្យម ដោយមានគ្លីនិកពិនិត្យជម្ងឺក្រៅពិសេសមួយចំនួន និងមានគ្រែសម្រាប់អ្នកជម្ងឺប្រហែល ១០០គ្រែ។ អ្នកជម្ងឺអាចវិនិច្ឆ័យរោគពីមណ្ឌលសុខភាពភូមិ ប្រសិនបើត្រូវការការថែទាំពិសេសត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យ។ ចំពោះសុខភាពមាតា និងកុមារ មន្ទីរពេទ្យផ្តល់សេវាដូចជា ការថែទាំមាតា ការថែទាំកុមារ និងផែនការគ្រួសារ។ មន្ទីរពេទ្យថែមទាំងដើរតួនាទីក្នុងការបណ្តុះបណ្តាលបុគ្គលិកថែទាំសុខភាពនៅតាម មណ្ឌលសុខភាពភូមិ ក៏ដូចជាការវិភាគ និងរក្សាទុកទិន្នន័យ។

#### ១-២. <u>មណ្ឌលសុខភាពភូមិ</u>

មណ្ឌលសុខភាពភូមិផ្តល់សេវាសុខភាពនានាទៅដល់សហគមន៍មានដូចជា ការព្យាបាលជម្ងឺទូទៅ ការផ្តល់ថ្នាំបង្ការោគ និងការឆ្លងទន្លេធម្មតា។ លើសពីនេះ មណ្ឌលសុខភាព ក៏ទទួលខុសត្រូវក្នុងការផ្តល់សកម្មភាពអប់រំសុខភាពនានាដល់ប្រជាជននៅក្នុងតំបន់ ប្រមូលទិន្នន័យស្ថិតិ និងរាយការណ៍ទៅមន្ទីរពេទ្យស្រុក។

## ២. បញ្ហានានាដែលបានកើតមាន

### ២-១. គុណភាពសេវាមានកម្រិតទាប

នៅក្នុងមណ្ឌលសុខភាព កំហុសឆ្គងក្នុងការវិនិច្ឆ័យរោគ និងការឆ្លងរោគបន្ទាប់ពីទទួលការព្យាបាល បានកើតឡើងដោយសារគិលានុបដ្ឋាយិការ និងឆ្មបខ្វះជំនាញ។ ការខ្វះជំនាញរបស់បុគ្គលិក ដោយសារមិនបានផ្តល់ការបណ្តុះបណ្តាលជាទៀងទាត់ និងការណែនាំផ្លាស់ប្តូរមិនបានធ្វើគ្រប់គ្រាន់។ មូលហេតុទាំងនេះ ធ្វើអោយមានឱកាសតិចតួចក្នុងការចូលរួមសិក្ខាសាលា និងការបណ្តុះបណ្តាល ការខ្វះខាតច្បាប់ការងារ និងប្រាក់ខែទាបបើធៀបទៅនិងបុគ្គលិកនៃស្ថាប័នព្យាបាលសុខភាពផ្សេងៗទៀត។

ផ្នែកបណ្តុះបណ្តាលនៃមន្ទីរពេទ្យស្រុក ទទួលបន្ទុកក្នុងការបណ្តុះបណ្តាលសមាជិកបុគ្គលិកមណ្ឌលសុខភាពភូមិ តាមរយៈការបណ្តុះបណ្តាលទូទៅ តាមដានការបណ្តុះបណ្តាល និងការបណ្តុះបណ្តាលស្តីពីសកម្មភាពអប់រំនានា។ បុគ្គលិកផ្នែក បណ្តុះបណ្តាលត្រូវបណ្តុះបណ្តាលបុគ្គលិកមណ្ឌលសុខភាពភូមិ។ ទោះបីជាយ៉ាងណាក៏ដោយ បុគ្គលិកផ្នែកបណ្តុះបណ្តាលមិនមានលទ្ធភាពអនុវត្តការទទួលខុសត្រូវរបស់ខ្លួនឡើយ ដោយសារមូលហេតុដូចខាងក្រោម។

- បុគ្គលិកមន្ទីរពេទ្យស្រុកខ្វះជំនាញសម្រាប់ការបណ្តុះបណ្តាល និងគ្រងគ្រង។
- ប្រព័ន្ធបណ្តុះបណ្តាលនៅមន្ទីរពេទ្យស្រុក រៀបចំមិនបានល្អ។
- ខ្លឹមសារ និងចំនួននៃការបណ្តុះបណ្តាលមិនសមស្រប ពីព្រោះបុគ្គលិកផ្នែកបណ្តុះបណ្តាលមិនយល់ច្បាស់ពីបច្ចេកទេស និងកម្រិតសមត្ថភាពរបស់បុគ្គលិកមណ្ឌលសុខភាពភូមិ។

### ២-២. ប្រជាជនក្នុងភូមិមានការលំបាកក្នុងការទទួលបានសេវាព្យាបាលនៅពេលចាំបាច់

លិខិតបទដ្ឋានថ្នាក់ជាតិ កំណត់ឱ្យមានគិលានុបដ្ឋាកយិការចំនួយពីរូប និងឆ្មបមួយរូបទៅបម្រើការក្នុងមណ្ឌលសុខភាពភូមិនីមួយៗ។ ទោះបីជាយ៉ាងនេះក្តី បុគ្គលិកដែលចាត់តាំងទៅមណ្ឌលសុខភាពភូមិនៅក្នុងស្រុក ខ មានតិចជាងតម្រូវការ។ មណ្ឌលសុខភាពខ្វះបុគ្គលិកថៃទាំសុខភាព ពីព្រោះគិលានុបដ្ឋាកយិការ និងឆ្មបភាគច្រើនចង់ធ្វើការនៅតំបន់ប្រជុំជន។

ការផ្គត់ផ្គង់ឱសថសម្រាប់ព្យាបាលក៏មិនគ្រប់គ្រាន់ដែរ ដោយសារថវិកាមណ្ឌលសុខភាពភូមិមានតិចតួច ហើយសម្ភារៈផ្គត់ផ្គង់ដែលមានប្រើប្រាស់នៅក្នុងភូមិមានកម្រិត។

## ២-៣. កត្តាអនាម័យរបស់មណ្ឌលសុខភាពភូមិមានកម្រិតទាប

បន្ថែមពីលើនេះ កត្តាអនាម័យរបស់មណ្ឌលសុខភាពភូមិភាគច្រើននៅមានកម្រិតទាប។ មូលហេតុមួយក្នុងចំណោមមូលហេតុនានា គឺអាគារមានសភាពទ្រុឌទ្រោម និងខ្វះខាតការថែទាំជាប្រចាំ បណ្តាលឲ្យស្ទះទបង្ហូរទឹក និងមានធូលីដី។ ជួនកាលបុគ្គលិកសុខាភិបាល ឬប្រជាជនក្នុងភូមិ ជូសជុលមណ្ឌលសុខភាពតាមការយល់ឃើញ ដោយគ្មានមាត្រដ្ឋានច្បាស់លាស់ពីស្ថានភាពសម្ភារៈបរិក្ខានានា។

## ២-៤. ស្ថានភាពលំបាករបស់ស្ត្រីក្នុងភូមិ

### ២-៤-១. ការទទួលបានព័ត៌មានចំពោះស្ត្រីនៅមានកម្រិត

នៅក្នុងស្រុក ខ ប្រជាជនជាច្រើនមិនយល់ដឹងពីសារៈសំខាន់នៃការអប់រំសម្រាប់ស្ត្រី ហើយស្ត្រីជាច្រើនមិនចូលរៀន និងមិនមានលទ្ធភាពចូលរៀន។ ការទទួលបានព័ត៌មានរបស់ស្ត្រីអំពីបញ្ហាសុខភាព និងបញ្ហាផ្សេងៗទៀតនៅមានកម្រិត ដោយសារការខ្វះឱកាសចេញក្រៅភូមិ និងមិនមានសារព័ត៌មានដូចជាកាសែត និងទស្សនាវដ្តីជាដើម។

### ២-៤-២. ការខ្វះនូវសកម្មភាពអប់រំសមស្របពីមណ្ឌលថែទាំសុខភាពភូមិ

នៅក្នុងភូមិជាច្រើនក្នុង ស្រុក ខ សកម្មភាពអប់រំនានាដែលផ្តល់ដោយមណ្ឌលសុខភាពភូមិទទួលបានការចាប់អារម្មណ៍តិចតួចណាស់ ពីព្រោះសុខភាពស្ត្រីមិនមែនជាអទិភាព។ បន្ថែមពីលើនេះ សកម្មភាពអប់រំនានានៅក្នុងភូមិមិនឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ស្ត្រី ដោយសារវាហួសសម័យ ហើយខ្វះខាតសម្ភារៈ និងបុគ្គលិកមានជំនាញ។

### ២-៤-២. ការធ្វើការច្រើនពេកចំពោះស្ត្រីមានផ្ទៃពោះ

នៅតំបន់ជនបទ និងតំបន់ភ្នំដែលស្ថិតក្រោមការគ្រប់គ្រងដោយព្រឹទ្ធាចារ្យដូចជាស្រុក ខ ការងាររបស់ស្ត្រី គឺធ្ងន់ធ្ងរណាស់។ ស្ត្រីត្រូវធ្វើទាំងការងារផ្ទះ និងការងារកសិកម្ម រួមទាំងការមើលថែទាំសត្វចិញ្ចឹម។ ស្ត្រីនៅក្នុងស្រុក ខ ត្រូវធ្វើការងារកសិកម្មធ្ងន់ៗ ពីព្រោះដីនៅទីនោះគ្មានជីជាតិ ហើយបច្ចេកទេសកសិកម្មគឺហួសសម័យ។ ការផ្លាស់ប្តូរការដាំដំណាំធ្វើឲ្យបញ្ហាកាន់តែធ្ងន់ធ្ងព្រោះដីកាន់តែឥតជីជាតិ ហើយចំណេះដឹង និងបច្ចេកទេសធ្វើជីនៅមានកម្រិត។ បន្ថែមពីលើនេះ ការងាររបស់ស្ត្រីមិនមានការកាត់បន្ថយទេក្នុងអំឡុងពេលមានផ្ទៃពោះ ដោយសារខ្វះការយល់ដឹងចំពោះស្ត្រីមានផ្ទៃពោះ និងដោយសារការចាំបាច់ផ្នែកសេដ្ឋកិច្ច។ ការធ្វើការច្រើនពេកចំពោះស្ត្រីមានផ្ទៃពោះដោយសារមូលហេតុទាំងនេះ ជាញឹកញាប់បណ្តាលឱ្យមានការឈឺចាប់ក្នុងរាង្គកាយ និងការរលូតកូន។

# ផ្នែកទី ៤

## ឈំហាត់៖

## ការបំពេញតារាង ក្នុងជំហានទី ១

## ផ្អែកតាមការវិភាគបញ្ហា/ការវិភាគ

## ដំណោះស្រាយ

គ.ជ.អ.ប
NCDD

JICA

# ផ្នែកទី ៤

## លំហាត់៖

## ការបំពេញតារាង ក្នុងជំហានទី ១ ផ្អែកតាមការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ

គម្រោងសម្រាប់កិច្ចអភិវឌ្ឍសមត្ថភាព
ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ
នៅថ្នាក់រាជធានី ខេត្ត (PILAC2)

# គោលបំណង និងមាតិកា

**គោលបំណងនៃផ្នែកទី ៤៖**

សិក្ខាកាមនឹងមានសមត្ថភាពបំពេញតារាង១.១ ដល់តារាង១.៤ ផ្អែកតាមការវិភាគបញ្ហា/ ការវិភាគរកដំណោះស្រាយ

**មាតិកា៖** ១.បទបង្ហាញ៖ វិធីបំពេញតារាង
២.លំហាត់

1

## តារាង១.១ នៃ CPDP

| វិស័យ និង សកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព |
|---|---|---|---|---|---|

១.ផ្នែកសេដ្ឋកិច្ច

២.ផ្នែកសង្គមកិច្ច

៣.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

៤.ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

2

## តារាង១.២ នៃ CPDP

| វិស័យ និងសេវា | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|---|

១.ផ្នែកសេដ្ឋកិច្ច

២.ផ្នែកសង្គមកិច្ច

៣.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

៤.ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

3

# តារាង១.៣ នៃ CPDP

| វិស័យ និងសេវា | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការ យេនឌ័រ |
|---|---|---|---|---|

១.ផ្នែកសេដ្ឋកិច្ច

២.ផ្នែកសង្គមកិច្ច

៣.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

៤.ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

4

# តារាង១.៤ នៃ CPDP

| វិស័យ | សក្តានុពល (ភាពខ្លាំង) | ឧបសគ្គ (ភាពខ្សោយ) | ការវិនិយោគ (ដំណោះស្រាយ) | តម្រូវការ យេនឌ័រ |
|---|---|---|---|---|

១.ផ្នែកសេដ្ឋកិច្ច

២.ផ្នែកសង្គមកិច្ច

៣.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

៤.ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

•

5

# វិន័យនៃការបំពេញតារាង

| ការវិភាគបញ្ហា និងការវិភាគរកដំណោះស្រាយ | តារាង១.១ ដល់តារាង១.៤ |
|---|---|
| បញ្ហាស្នូល | បញ្ហា |
| មូលហេតុផ្ទាល់ | មូលហេតុ |
| មូលហេតុរង | ------------------------------------ |
| គោលដៅ | សកម្មភាព ឬសេវា |
| គោលបំណង | ------------------------------------ |
| គោលបំណងរង | ដំណោះស្រាយ |

- មូលហេតុរងក៏អាចប្រើប្រាស់ជាមូលហេតុនៃតារាង១.១ ដល់តារាង១.៤ នៃ CPDP ។
- ត្រូវពឹងផ្អែកទៅលើទំហំនៃសកម្មភាព។ នៅពេលមូលហេតុផ្ទាល់ត្រូវបានចាត់ទុកថាជាបញ្ហាធំធេងសម្រាប់រាជធានី ខេត្តពាក់ព័ន្ធ មូលហេតុរងអាចចាត់ទុកថាជាមូលហេតុនៃតារាងរបស់ CPDP ។

6

# ឧទាហរណ៍នៃការបំពេញតារាង

| វិស័យ និង សកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការ យេនឌ័រ | អាទិភាព |
|---|---|---|---|---|---|
| ១. ផ្នែកសេដ្ឋកិច្ច | | | | | |
| (វិស័យកសិកម្ម) សកម្មភាព៖<br><br>សត្វពាហនៈនៅក្នុងភូមិមានសុខភាពល្អ | សត្វពាហនៈ នៅក្នុងភូមិស្លាប់ ដោយសារជំងឺអុតក្តាម | ១. ប្រជាពលរដ្ឋខ្វះចំណេះដឹងអំពីជំងឺអុតក្តាម<br>២. ការឆ្លើយតបរបស់មេឃុំមិនទាន់ពេលវេលា<br>៣. មន្ត្រីបសុពេទ្យផ្តល់សេវាមិនបានល្អ<br>៤.ប្រជាពលរដ្ឋមិនអាចអញ្ជើញពេទ្យសត្វបាន | ១.១ផ្សព្វផ្សាយអំពីជំងឺសត្វដល់ប្រជាពលរដ្ឋ<br>២.១បណ្តុះបណ្តាលឃុំអំពីអភិបាលកិច្ចល្អ<br>៣.១ពង្រឹងរបៀបរបបការងាររបស់មន្ទីរ<br>៤.១បង្កើតពេទ្យសត្វសហគមន៍សម្រាប់ប្រជាពលរដ្ឋ | ១. ស្ត្រីហាក់មានឱកាសតិចក្នុងការទទួល ពត៌មានអំពីជំងឺសត្វ | |

## បូកសរុបតារាង ១.១ ដល់តារាង១.៤ ទៅតារាង១.៥ ដល់តារាង១.៨

តារាង១.១ ដោយស្រុក ក



តារាង១.១ ដោយស្រុក ខ



តារាង១.៥

| វិស័យ និងសកម្មភាព | ដំណោះស្រាយ | អាទិភាពក្រុង ស្រុក ខណ្ឌ | | | អាទិភាពជាមធ្យម |
|---|---|---|---|---|---|
| | | ស្រុក... | ស្រុក... | ស្រុក... | |

១.ផ្នែកសេដ្ឋកិច្ច

២.ផ្នែកសង្គមកិច្ច

៣.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

៤.ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

តារាង ១.១ -> តារាង ១.៥
តារាង ១.២ -> តារាង ១.៦
តារាង ១.៣ -> តារាង ១.៧
តារាង ១.៤ -> តារាង ១.៨

8

## តារាង១.៥ នៃ CPDP

| វិស័យ និងសកម្មភាព | ដំណោះស្រាយ | អាទិភាពក្រុង ស្រុក ខណ្ឌ | | | អាទិភាពជាមធ្យម |
|---|---|---|---|---|---|
| | | ស្រុក... | ស្រុក... | ស្រុក... | |

១.ផ្នែកសេដ្ឋកិច្ច

២.ផ្នែកសង្គមកិច្ច

៣.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

៤.ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

9

# តារាង១.៦ នៃ CPDP

| វិស័យ និងសេវា | ដំណោះស្រាយ | ឈ្មោះមន្ទីរ អង្គភាព | | | ចំនួនមន្ទីរ ដែលបានស្នើ |
|---|---|---|---|---|---|
| | | មន្ទីរ... | មន្ទីរ... | មន្ទីរ... | |

១.ផ្នែកសេដ្ឋកិច្ច

២.ផ្នែកសង្គមកិច្ច

៣.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

៤.ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

10

# តារាង១.៧ នៃ CPDP

| វិស័យ និងសេវា | ដំណោះស្រាយ | ឈ្មោះអង្គការ | | | ចំនួនអង្គការ ដែលបានស្នើ |
|---|---|---|---|---|---|
| | | អង្គការ... | អង្គការ... | អង្គការ... | |

១.ផ្នែកសេដ្ឋកិច្ច

២.ផ្នែកសង្គមកិច្ច

៣.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

៤.ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

11

# តារាង១.៨ នៃ CPDP

| វិស័យ និងសេវា \ | ដំណោះស្រាយ | ឈ្មោះក្រុមហ៊ុន | | | ចំនួនក្រុមហ៊ុនដែលបានស្នើ |
|---|---|---|---|---|---|
| | | ក្រុមហ៊ុន... | ក្រុមហ៊ុន.. | ក្រុមហ៊ុន.... | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | |
| ២.ផ្នែកសង្គមកិច្ច | | | | | |
| ៣.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | | | | | |
| ៤.ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | |

12

# លំហាត់

១)សមាជិកក្នុងក្រុមដដែលនៅក្នុងផ្នែកទី ៣ បន្តធ្វើការជាមួយគ្នា។ (ក្រុម ក និងក្រុម ខ)

២)ស្នើសុំឲ្យក្រុមនីមួយៗ បំពេញតារាង១.១ ផ្អែកតាមលទ្ធផលនៃលំហាត់ (ដើមឈើបញ្ហា/ដើមឈើដំណោះស្រាយ) ក្នុងផ្នែកទី៣ និងដើមឈើបញ្ហា/ដើមឈើដំណោះស្រាយបន្ថែមទៀត។

៣)តារាងនានាដែលបានរៀបចំរួចរាល់កាលពីជំហានមុនៗ ត្រូវបូកសរុបទៅក្នុងតារាង១.៥។

(៨០នាទី)

13

# សូមអរគុណ!

## ផ្នែកទី៤- ឯកសារចែកជូន

**ក្រុម ក**

**ការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ ១ ៖ បញ្ហាការផ្គត់ផ្គង់ទឹក (សូមចម្លងពីផ្នែកទី៣)**

## ការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ ២ ៖ បញ្ហាសុខភាព

### ការវិភាគបញ្ហា




### ការវិភាគដំណោះស្រាយ



## ការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ ៣ ៖ បញ្ហាសន្តិសុខ

### ការវិភាគបញ្ហា




### ការវិភាគរកដំណោះស្រាយ



## រចនាសម្ព័ន្ធ នៃផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (CPDP)

ប្រធានក្រុមប្រឹក្សាត្រូវ ចុះហត្ថលេខាលើអារម្ភកថា

ជំហានទី៣/៣-៤ ការសរសេរសេចក្តីព្រាង CPDP

ឯកសារស្តីពី CPDP ដែលទូលំទូលាយ ត្រូវបានធ្វើសេចក្តីព្រាង នៅជំហានទី ៣ / ៣-៤

- សេចក្តីសម្រេចស្តីពីដាក់ឲ្យប្រើប្រាស់ CPDP
- អារម្ភកថា
- សេចក្តីផ្តើម
- ដែនទីរាជធានី ខេត្ត
- **ជំពូកទី១៖ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច**
- ១.១ សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច
- ១.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម
  - ១.២.១ ស្ថានភាពសេដ្ឋកិច្ច
  - ១.២.២ ស្ថានភាពសង្គមកិច្ច
  - ១.២.៣ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន
  - ១.២.៤ ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ
  - ១.២.៥ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ
- **ជំពូកទី២៖ ក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានីខេត្ត**
- ២.១ ចក្ខុវិស័យអភិវឌ្ឍន៍
- ២.២ គោលដៅអភិវឌ្ឍន៍
- ២.៣ គោលបំណងអភិវឌ្ឍន៍
- ២.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍
  - ២.៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច
  - ២.៤.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គម
  - ២.៤.៣ យុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន
  - ២.៤.៤ យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះមហន្តរាយ និង ការប្រែប្រួលអាកាសធាតុ
  - ២.៤.៥ យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ
- ២.៥ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- **ជំពូកទី៣៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍**
- **ឧបសម្ព័ន្ធ**

ជំហានទី១/១-៥រៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា

ផ្នែកនេះ៖ រៀបចំដោយផ្អែកលើតារាងទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

ជំហានទី៣/៣-១ ការវិភាគស្ថានភាពរាជធានីខេត្ត

ផ្នែកនេះ៖ រៀបចំដោយផ្អែកលើតារាង២.១ ដល់ តារាង២.១១

ជំហានទី៣/៣-២ ការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានីខេត្ត

ផ្នែកនេះរៀបចំ ដោយផ្អែកតាម តារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងរៀបចំ សេចក្តីណែនាំលម្អិត នៅពេលក្រោយៗ

ជំហានទី៣/៣-៣ ការរៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍

ដោយសារសេចក្តីណែនាំបច្ចេកទេស មិនបានកំណត់វិធីសាស្ត្រ និងទម្រង់បែបបទ ជាក់លាក់ណាមួយ វិធីសាស្ត្រ និងទម្រង់បែបបទ ជាបណ្តោះអាសន្នមួយ ត្រូវបានបង្ហាញក្នុង វគ្គបណ្តុះបណ្តាល (ផ្នែកទី ៧ នៃវគ្គបណ្តុះបណ្តាល ថ្នាក់រាជធានី ខេត្ត

# ផ្នែកទី ៥

## គោលការណ៍ណែនាំ

## ផ្នែកគោលនយោបាយ

គ.ជ.អ.ប
NCDD

JICA

# ផ្នែកទី ៥

## គោលការណ៍ណែនាំផ្នែកគោលនយោបាយ

គម្រោងសម្រាប់កិច្ចអភិវឌ្ឍសមត្ថភាព
ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ
នៅថ្នាក់រាជធានី ខេត្ត (PILAC 2)

# គោលបំណង និងមាតិកា

គោលបំណងនៃផ្នែកទី ៥៖

សិក្ខាកាមនឹងយល់ពីទិន្នន័យដែលមានស្រាប់ដើម្បីរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ

មាតិកា៖

១. គោលការណ៍ណែនាំផ្នែកគោលនយោបាយនៃ CPDP

២.នីតិវិធីដើម្បីកំណត់សកម្មភាព និងតំបន់អាទិភាព

## ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត

១-២. ការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ រាជធានី ខេត្ត

*គោលបំណង*

រៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ

*សមាសភាព*

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត (PWG)
- គណៈអភិបាលរាជធានី ខេត្ត (BOG)
- ក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈកម្មាធិការពាក់ព័ន្ធនានា

*លទ្ធផល*

- គោលការណ៍ណែនាំផ្នែកគោលនយោបាយ និងតារាង ១.៥ តារាង ១.៦ តារាង១.៧ និងតារាង១.៨

2

## គោលបំណងនៃគោលការណ៍ណែនាំផ្នែកគោលនយោបាយ

- គោលបំណងនៃគោលការណ៍ណែនាំផ្នែកគោលនយោបាយ គឺដើម្បីតម្រង់ទិស វិស័យនិងសកម្មភាពជាអាទិភាព និងតំបន់អាទិភាពនានា ក្នុងដំណើរការកសាង CPDP។

- PWG ត្រូវប្រើប្រាស់ទិន្នន័យ និងព័ត៌មានជាឯកសារយោងសម្រាប់រៀបចំសេចក្ដីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយ

## អនុសាសន៍ក្នុងការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ

សកម្មភាពសំខាន់ៗ រួមមាន៖

១. ពិនិត្យតារាង១.៥ ដល់តារាង១.៨

២. ពិនិត្យលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (NSDP) ២០០៩-២០១៣

៣. ពិនិត្យគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា (CMDGs) និងតារាងពិន្ទុ CMDG

4

## ១. ពិនិត្យតារាង១.៥ ដល់តារាង១.៨

- វិស័យ និងសកម្មភាព ឬសេវា ដែលមានចំណាត់អាទិភាពមធ្យម ខ្ពស់ ឬចំនួនស្ថាប័នស្នើគម្រោងច្រើន ត្រូវបានអ្នកពាក់ព័ន្ធចាត់ទុកថាមានអាទិភាពខ្ពស់។

5

## ២. ពិនិត្យលើផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ បច្ចុប្បន្នកម្ម (NSDP)

- ពិនិត្យតារាងសង្ខេបៈ សូចនាករសំខាន់ៗ នៃ NSDP ២០០៦-២០១០ (គោលដៅ)
- ពិនិត្យសូចនាករមធ្យមភាគរាជធានី ខេត្ត ដើម្បីឆ្លើយតបទៅនឹងសូចនាករសំខាន់ៗ នៃ NSDP២០០៦-២០១០ (គោលដៅ)
- សូចនាករមធ្យមភាគរាជធានី ខេត្ត ដែលមានកម្រិតទាបជាង គោលដៅជាតិ អាចចាត់ទុកថាជាតំបន់/វិស័យអាទិភាព។

6

## ៣. ពិនិត្យគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា (CMDGs) និងតារាងពិន្ទុ CMDG

១.ប្រៀបធៀបពិន្ទុ CMDG នៃរាជធានី ខេត្តពាក់ព័ន្ធជាមួយនឹងរាជធានី ខេត្តផ្សេងៗទៀត
២. តំបន់ដែលមានពិន្ទុទាបអាចចាត់ទុកថាមានអាទិភាព។

- មន្ទីរផែនការទទួលខុសត្រូវលើតារាងពិន្ទុ CMDGs។ ដូចនេះ មន្ទីរផែនការ ត្រូវបានស្នើសុំឲ្យផ្ញើរតារាងពិន្ទុ CMDG ទៅឲ្យក្រុមការងារកសាងផែនការ។

7

# សូមអរគុណ!

3

# ឯកសារចែកជូន ផ្នែកទី៥

## ១. ព័ត៌មានពីក្រុង / ស្រុក

* តារាងខាងក្រោម ត្រូវបានរៀបចំដោយផ្អែកលើឯកសារចែកជូនផ្នែកទី ៤ /ដើមឈើបញ្ហា /ដើមឈើដំណោះស្រាយ។

| **ក្រុង ក** | |
|---|---|
| វិស័យសុខាភិបាល | គុណភាព និងបរិមាណទឹក មិនទទួលបានការពេញចិត្ត។ |
| វិស័យបរិស្ថាន | ប្រជាជនជាច្រើនដែលរស់នៅតាមដងទន្លេ មានជម្ងឺ។ |
| វិស័យសន្តិសុខ | ប្រជាជនជាច្រើន ប្រឈមនឹងគ្រោះថ្នាក់ដោយសារ ឧក្រិដ្ឋកម្ម។ |

| **ស្រុក ខ** | |
|---|---|
| វិស័យសុខាភិបាល | អត្រាមរណៈភាពរបស់មាតា មានកម្រិតខ្ពស់។ |
| វិស័យកសិកម្ម | ចំណូលពីការធ្វើស្រែ ទាប។ |
| វិស័យអប់រំ | កូនសិស្សជាច្រើន ឈប់រៀននៅថ្នាក់ទី៦។ |

| **ស្រុក គ** | |
|---|---|
| វិស័យកសិកម្ម | ការចិញ្ចឹមសត្វស្រុក មិនមានផលចំណេញ។ |
| វិស័យសុខាភិបាល | ទារកជាច្រើន ខ្វះអាហាររូបត្ថម្ភ។ |
| វិស័យអប់រំ | កូនសិស្សជាច្រើន ឈប់រៀននៅថ្នាក់ទី៦។ |

| **ស្រុក ឃ** | |
|---|---|
| វិស័យកសិកម្ម | ចំណូលពីការធ្វើស្រែ ទាប។ |
| វិស័យកសិកម្ម | ការចិញ្ចឹមសត្វស្រុក មិនមានផលចំណេញ។ |
| វិស័យអប់រំ | កូនសិស្សជាច្រើន ឈប់រៀននៅថ្នាក់ទី៦។ |

<u>តារាងសំយោគ</u>

| **ទិសស័យ** | **បញ្ហាដែលរកឃើញ** | **កំណត់លេខ** |
|---|---|---|
| **វិស័យសុខាភិបាល** | គុណភាព និងបរិមាណទឹក មិនទទួលបានការពេញចិត្ត។ | ១ |
| | អត្រាមរណៈភាពរបស់មាតា មានកម្រិតខ្ពស់។ | ១ |
| | ទារកជាច្រើន ខ្វះអាហាររូបត្ថម្ភ។ | ១ |
| **វិស័យកសិកម្ម** | ចំណូលពីការធ្វើស្រែ ទាប។ | ២ |
| | ការចិញ្ចឹមសត្វស្រុក មិនមានផលចំណេញ។ | ២ |
| **វិស័យបរិស្ថាន** | ប្រជាជនជាច្រើនដែលរស់នៅតាមដងទន្លេ មានជម្ងឺ។ | ១ |
| **វិស័យសន្តិសុខ** | ប្រជាជនជាច្រើន ប្រឈមនឹងគ្រោះថ្នាក់ដោយសារឧក្រិដ្ឋកម្ម។ | ១ |
| **វិស័យអប់រំ** | កូនសិស្សជាច្រើន ឈប់រៀននៅថ្នាក់ទី៦។ | ៣ |

<u>អាទិភាព ត្រូវផ្អែកលើតារាងសំយោគ</u>

១) វិស័យអប់រំ ជាពិសេសបញ្ហាឈប់រៀនរបស់កូនសិស្សបឋមសិក្សា ត្រូវបានចាត់ទុកថាជាបញ្ហាព្រួយបារម្ភខ្ពស់។ (៣)

២) វិស័យកសិកម្ម ដែលទាក់ទងនឹងការចិញ្ចឹមសត្វស្រុក និងការធ្វើស្រែ ត្រូវបានចាត់ទុកថាជាបញ្ហាព្រួយបារម្ភបន្ទាប់។ (២+២=៤)

៣) វិស័យសុខាភិបាល ត្រូវបានចាត់ទុកថាជាបញ្ហាព្រួយបារម្ភខ្ពស់ផងដែរ។ (១+១+១=៣)

* **<u>អនុសាសន៍៖ បញ្ហាព្រួយបារម្ភចំនួនប្រាំ ត្រូវកំណត់ក្នុងស្ថានភាពជាក់ស្តែង។</u>**

## ២. ប្រៀបធៀប រវាងគោលដៅថ្នាក់ជាតិ និងមធ្យមភាគនៃបញ្ហាប្រឈមបារម្ភ

* សន្មតថា ព័ត៌មានខាងលើ ត្រូវបានប្រមូលនៅក្នុងខេត្តមណ្ឌលគីរី ដូចនេះ ការប្រៀបធៀប ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| វិស័យ | បញ្ហាដែលរកឃើញ | គោលដៅ CMDG-2015 * | ខេត្តមណ្ឌលគីរី ** |
|---|---|---|---|
| វិស័យសុខាភិបាល | គុណភាព និងបរិមាណទឹក មិនទទួលបានការពេញចិត្ត។ | 50.09% សម្គាល់ ១ | 82% សម្គាល់ ៦ |
| | អត្រាមរណភាពរបស់មាតា មានកម្រិតខ្ពស់។ | 250 សម្គាល់ ២ | 7,138 សម្គាល់ ៧ |
| | ទារកជាច្រើន ខ្វះអាហារូបត្ថម្ភ។ | 22% សម្គាល់ ៣ | អត់មាន |
| វិស័យកសិកម្ម | ចំណូលពីការធ្វើស្រែ ទាប។ | 3.0 សម្គាល់ ៤ | 1.0 សម្គាល់ ៨ |
| | ការចិញ្ចឹមសត្វស្រុក មិនមានផលចំណេញ។ | អត់មាន | អត់មាន |
| វិស័យអប់រំ | កូនសិស្សជាច្រើន ឈប់រៀននៅថ្នាក់ទី៦។ | 100% សម្គាល់ ៥ | 72% សម្គាល់ ៩ |

សម្គាល់ ១ ៖ ច្រើនជាង 50.09% នៃប្រជាជនរស់នៅជនបទ មានទឹកស្អាតប្រើប្រាស់។

សម្គាល់ ២ ៖ អត្រាមរណភាពនៃស្ត្រីសម្រាលកូនដែលចង់សម្រេចបាន គឺតិចជាង 250 នាក់ ក្នុង 100,000 កំណើត។

សម្គាល់ ៣ ៖ តិចជាង 22% នៃក្មេងអាយុពី 0-59 ខែ មិនមានការលូតលាស់យ៉ាងធ្ងន់ធ្ងរ ឬជាមធ្យម។

សម្គាល់ ៤ ៖ សម្រេចអោយបានច្រើនជាង 3.0 តោន នៅមួយហិចតា។

សម្គាល់ ៥ ៖ អត្រាបញ្ចប់ថ្នាក់ទី៦ ឈានដល់ 100%។

សម្គាល់ ៦ ៖ អត្រាភាគរយនេះ រួមបញ្ចូលគ្រួសារដែលប្រើប្រាស់ឧបករណ៍ចម្រោះទឹក និងទឹកដាំពុះ សម្រាប់បរិភោគ នៅឆ្នាំ២០០៨។

សម្គាល់ ៧ ៖ អត្រាមរណភាពមាតាក្រោយពេលសម្រាល (0-១ខែ) ក្នុង 100,000 កំណើត នៅឆ្នាំ២០០៨។

សម្គាល់ ៨ ៖ ទិន្នផលស្រូវវស្សាជាមធ្យម នៅឆ្នាំ២០០៨។

សម្គាល់ ៩ ៖ ភាគរយនៃកុមារអាយុពី ៦-១១ ឆ្នាំ កំពុងរៀន នៅឆ្នាំ២០០៨។

* គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ឆ្នាំ២០១៥ (CMDGs-2015) ត្រូវបានបង្ហាញនៅក្នុងតារាង ២៧៖ សូចនាករសំខាន់ៗនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ (គោលដៅ) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ ហើយតួលេខទាំងនោះ ត្រូវបានចាត់ទុកថាជាគោលដៅថ្នាក់ជាតិ រហូតដល់ឆ្នាំ២០១៥។

** ទិន្នន័យទាំងនេះ បានស្រង់មកពីសៀវភៅទិន្នន័យខេត្តមណ្ឌលគីរីឆ្នាំ២០០៩ ដែលរៀបចំដោយ គ.ជ.អ.ប។

**<u>អាទិភាពផ្អែកលើការប្រៀបធៀប</u>**

១) សូចនាករដែលទាក់ទងនឹង "ចំណូលពីការធ្វើស្រែ" មានកម្រិតទាបជាងគោលដៅថ្នាក់ជាតិ។ ដូច្នេះបញ្ហាទិន្នផលស្រូវ ត្រូវចាត់ទុកថាជាអាទិភាព។

២) សូចនាករដែលទាក់ទងនឹង "សិស្សជាច្រើនឈប់រៀននៅថ្នាក់ទី៦" មានកម្រិតទាបជាងគោលដៅថ្នាក់ជាតិ។ បញ្ហានេះ ត្រូវចាត់ទុកថាជាអាទិភាព។

## ៣. តារាងពិន្ទុគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ( CDMGs Scorecard )

ការដាក់ពិន្ទុមានដូចខាងក្រោម៖

**ខ្ពស់** (អាទិភាពខ្ពស់) ៖ រាជធានី ខេត្តពាក់ព័ន្ធ ដែលមានចំណាត់ថ្នាក់ទាបបំផុតក្នុងមួយភាគបីចុងក្រោយនៃរាជធានី ខេត្ត (១៧-២៤)

**មធ្យម** (អាទិភាពមធ្យម) ៖ រាជធានី ខេត្តពាក់ព័ន្ធ ដែលមានចំណាត់ថ្នាក់កណ្តាលក្នុងមួយភាគបីនៃ រាជធានី ខេត្ត (៩-១៦)

**ទាប** (អាទិភាពទាប) ៖ រាជធានី ខេត្តពាក់ព័ន្ធ ដែលមានចំណាត់ថ្នាក់ខ្ពស់បំផុតក្នុងមួយភាគបីនៃ រាជធានី ខេត្ត (១-៨)

**តារាង លើកកម្ពស់សុខភាពមាតា**




**តារាង សម្រេចឱ្យបានជាទូទៅនូវការអប់រំមូលដ្ឋាន**




| ល.រ | អក្សរកាត់ | ឈ្មោះខេត្ត | ល.រ | អក្សរកាត់ | ឈ្មោះខេត្ត | ល.រ | អក្សរកាត់ | ឈ្មោះខេត្ត |
|---|---|---|---|---|---|---|---|---|
| 1 | BMC | បន្ទាយមានជ័យ | 9 | KKG | កោះកុង | 17 | SRP | សៀមរាប |
| 2 | BAT | បាត់ដំបង | 10 | KRT | ក្រចេះ | 18 | SHV | ព្រះសីហនុ |
| 3 | KPC | កំពង់ចាម | 11 | MKR | មណ្ឌលគីរី | 19 | STG | ស្ទឹងត្រែង |
| 4 | KCH | កំពង់ឆ្នាំង | 12 | PNP | ភ្នំពេញ | 20 | SVR | ស្វាយរៀង |
| 5 | KSP | កំពង់ស្ពឺ | 13 | PVR | ព្រះវិហារ | 21 | TAK | តាកែវ |
| 6 | KPT | កំពង់ធំ | 14 | PVG | ព្រៃវែង | 22 | OMC | ឧត្តរមានជ័យ |
| 7 | KAM | កំពត | 15 | PUR | ពោធិ៍សាត់ | 23 | KEP | កែប |
| 8 | KDL | កណ្តាល | 16 | RAT | រតនះគីរី | 24 | PLN | ប៉ៃលិន |

| វិស័យ | បញ្ហាដែលរកឃើញ | តារាងពិន្ទុ CMDGs |
|---|---|---|
| វិស័យសុខាភិបាល | គុណភាព និងបរិមាណទឹក មិនទទួលបានការពេញចិត្ត។ | ទាប |
| | អត្រាមរណភាពរបស់មាតា មានកម្រិតខ្ពស់។ | ខ្ពស់ |
| | ទារកជាច្រើន ខ្វះអាហាររូបត្ថម្ភ។ | អត់មាន |
| វិស័យកសិកម្ម | ចំណូលពីការធ្វើស្រែ ទាប។ | អត់មាន |
| | ការចិញ្ចឹមសត្វស្រុក មិនមានផលចំណេញ។ | អត់មាន |
| វិស័យអប់រំ | កូនសិស្សជាច្រើន ឈប់រៀននៅថ្នាក់ទី៦។ | ខ្ពស់ |

<u>អាទិភាពផ្អែកលើតារាងពិន្ទុគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CDMGs Scorecard)</u>

ផ្អែកតាម *តារាងលើកកម្ពស់សុខភាពមាតា* និង *តារាងសម្រេចឱ្យបានជាទូទៅនូវការអប់រំមូលដ្ឋាន* យើងសង្កេតឃើញថា ខេត្តមណ្ឌលគីរី ស្ថិតនៅក្នុងចំណាត់ថ្នាក់ទី២១ និង ២៣ ពោលគឺស្ថិតក្នុងចំណាត់ថ្នាក់ទាបបំផុតមួយភាគបីចុងក្រោយ ហេតុនេះ៖

១) "អត្រាមរណភាពមាតា មានកម្រិតខ្ពស់" ត្រូវចាត់ទុកថាមានអាទិភាពខ្ពស់។

២) "សិស្សជាច្រើនឈប់រៀននៅថ្នាក់ទី៦" ត្រូវចាត់ទុកថាមានអាទិភាពខ្ពស់។

## ៤. សេចក្តីសន្និដ្ឋាន

១) អាទិភាពខ្ពស់បំផុត ត្រូវបានផ្តល់ឱ្យ "អត្រាមរណភាពមាតា មានកម្រិតខ្ពស់" ឬ វិស័យសុខាភិបាល និង "សិស្សជាច្រើនឈប់រៀននៅថ្នាក់ទី៦" ឬ វិស័យអប់រំ។

២) អាទិភាពទី២ ត្រូវបានផ្តល់ឱ្យ "ចំណូលពីការធ្វើស្រែ ទាប" ឬ វិស័យកសិកម្ម។

៣) "គុណភាព និងបរិមាណទឹក មិនទទួលបានការពេញចិត្ត" ឬ វិស័យសុខាភិបាល "ទារកជាច្រើន ខ្វះអាហាររូបត្ថម្ភ" ឬ វិស័យសុខាភិបាល "ការចិញ្ចឹមសត្វស្រុក មិនមានផលចំណេញ" ឬ វិស័យកសិកម្ម ត្រូវធ្វើការពិចារណាឱ្យសមហេតុផល។

# ផ្នែកទី ៦

## ប្រតិទិនការងារសម្រាប់ដំណើរការ

## កសាងផែនការអភិវឌ្ឍន៍

គ.ជ.អ.ប
NCDD

# ផ្នែកទី ៦

## ប្រតិទិនការងារសម្រាប់ដំណើរការ កសាងផែនការអភិវឌ្ឍន៍

គម្រោងសម្រាប់កិច្ចអភិវឌ្ឍសមត្ថភាព
ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ
នៅថ្នាក់រាជធានី ខេត្ត (PILAC 2)

# គោលបំណង និងមាតិកា

**គោលបំណងនៃផ្នែកទី ៦៖**

សិក្ខាកាមនឹងយល់ពីប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍។

**មាតិកា៖**

១- ប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍

២- អនុសាសន៍ពីដំណើរការកសាងផែនការ

1

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

## ១-៣ ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍

*គោលបំណង*

រៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍

*សមាសភាព*

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត (PWG)
- គណៈអភិបាលរាជធានី ខេត្ត (BOG)
- ក្រុមប្រឹក្សារាជធានី ខេត្ត

*លទ្ធផល*

- ប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍

2

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

## ១-៣. ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ (បន្ត)

| ល.រ | សកម្មភាព | ពេលវេលា | ទីកន្លែង | អ្នកទទួលខុសត្រូវ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|

ប្រតិទិនការងារកសាងផែនការខាងលើនេះ ត្រូវបានក្រុមប្រឹក្សារាជធានី ខេត្ត ______អនុម័តក្នុងកិច្ចប្រជុំ ________លើកទី_____នាថ្ងៃទី______ ______ខែ_____ឆ្នាំ_____។

**ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត**

3

## ទំនាក់ទំនងផែនការសកម្មភាពក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត




## ដ្យាក្រាមភ្ជាប់សកម្មភាពសម្រាប់ដំណើរការនៃការកសាង CPDP និង CPIP

សូមពិនិត្យមើលឯកសារដែលបានចែកជូន៖ ដ្យាក្រាមភ្ជាប់សកម្មភាពសម្រាប់ដំណើរការនៃការកសាង CPDP និង CPIP Handout_Session6_GanttChart CPDP & CPIP_K.xlsx



5

## អនុសាសន៍ស្តីពីដំណើរការ

- នីតិវិធីខាងក្រោមនេះ គឺជាអនុសាសន៍សម្រាប់ការរៀបចំប្រតិទិនការងារកសាងផែនការ

១. រៀបចំទម្រង់តំរូឯកសារចែកជូនដូចៗគ្នា៖ ដ្យាក្រាមភ្ជាប់សកម្មភាពសម្រាប់ដំណើរការនៃការកសាង CPDP និង CPIP
២. ពិនិត្យសកម្មភាព (ជួរឈរខាងឆ្វេង) និងសកម្មភាពបន្ថែមផ្សេងៗទៀត ប្រសិនបើចាំបាច់។
៣. កំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំផ្លូវការដែលបង្ហាញពីដ្យាក្រាមភ្ជាប់សកម្មភាពសម្រាប់ដំណើរការនៃការកសាង CPDP និង CPIP (ឧទា៖ ១-១ កិច្ចប្រជុំណែនាំ  ២-៤ ការរៀបចំសិក្ខាសាលាសមាហរណកម្ម)
៤. គូបន្ទាត់សម្រាប់ថ្ងៃសំខាន់ៗនៅក្នុងសកម្មភាពនីមួយៗ
៥. បង្ហៃរព័ត៌មានទៅក្នុងតារាងនៃការរៀបចំប្រតិទិនការងារកសាងផែនការ

6

## សូមអរគុណ!

7

ដ្យាក្រាមគ្រាប់សកម្មភាពសម្រាប់ដំណើរការនៃការកសាង CPDP និង CPIP ជាបណ្តោះអាសន្ន

ឆ្នាំទី១




**ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត (CPDP)**

**ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ដំណើរការនៃផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

- ១.១ កិច្ចប្រជុំណែនាំ
- ១.២ ការរៀបចំគោលការណ៍ណែនាំថ្នាក់គោលនយោបាយ
- ១.៣ ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍
- ១.៤ ការរៀបចំរចនាសម្ព័ន្ធរបស់រាជធានី ខេត្តក្នុងការឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- ១.៥ ការរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា

**ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

**ជំហានទី ៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

- ៣.១ ការវិភាគស្ថានភាពរាជធានី ខេត្ត
- ៣.២ ការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត
- ៣.៣ ការរៀបចំយុទ្ធសាស្ត្រតាមវិស័យ ក្រុមនីតិវិធី និងការតាមដានការអនុវត្ត ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ៣.៤ ការសរសេរសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ៣.៥ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ៣.៦ ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលរាជធានី ខេត្តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ៣.៧ ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី ខេត្ត លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**ជំហានទី ៤៖ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

- ៤.១ ការងារមុនសម័យប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត
- ៤.២ ការប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត
- ៤.៣ ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

**កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (CPIP)**

**ជំហានទី ១៖ ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

- ១.១ ការកំណត់ និងការរៀបចំសំណើគម្រោង
- ១.២ ការពិនិត្យសំណើគម្រោង
- ១.៣ ការគណនាអត្ថប្រយោជន៍របស់គម្រោង
- ១.៤ រៀបចំសេចក្តីព្រាងបញ្ជីសំណើគម្រោងរបស់រាជធានី ខេត្ត
- ១.៥ កិច្ចប្រជុំពិនិត្យសេចក្តីព្រាងបញ្ជីសំណើគម្រោងរាជធានី ខេត្ត

**ជំហានទី ២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

- ២.១ ការរៀបចំវេទិកាស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច
- ២.២ ការរៀបចំគម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ២.៣ ការប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ២.៤ ការរៀបចំសិក្ខាសាលាសមាហរណកម្មនៃកម្មវិធីវិនិយោគរាជធានី ខេត្ត
- ២.៥ ការជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់ថវិកាវិនិយោគរាជធានី ខេត្ត
- ២.៦ ការរៀបចំបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ២.៧ ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលរាជធានី ខេត្ត លើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ២.៨ ការពិនិត្យ និងផ្តល់យោបល់របស់ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស រាជធានី ខេត្ត លើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត។

**ជំហានទី ៣៖ ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

- ៣.១ ការងារត្រៀមសម្រាប់ការប្រជុំអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ៣.២ ការងារក្នុងពេលប្រជុំអនុម័តកម្មវិធីវិនិយោគបី ឆ្នាំរំកិលរាជធានី ខេត្ត
- ៣.៣ ការងារក្រោយពេលប្រជុំអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត

# ផ្នែកទី ៧

## ដំណើរការកសាងផែនការអភិវឌ្ឍន៍

## រយៈពេលប្រាំឆ្នាំ ជំហានទី ២

## ជំហានទី ៣ និងជំហានទី ៤

គ.ជ.អ.ប
NCDD

# ផ្នែកទី ៧

## ដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ

## ជំហានទី ២ ជំហានទី ៣ និងជំហានទី ៤

គម្រោងសម្រាប់កិច្ចអភិវឌ្ឍសមត្ថភាព
ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ
នៅថ្នាក់រាជធានី ខេត្ត (PILAC 2)

# គោលបំណង និងមាតិកា

**គោលបំណងនៃផ្នែកទី ៧៖**

សិក្ខាកាមនឹងយល់ពីដំណើរការកសាងផែនការ
អភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (CPDP)
ជំហានទី ២ ជំហានទី ៣ និងជំហានទី ៤

**មាតិកា៖**

១. ដំណើរការកសាង CPDP
ជំហានទី ២ ជំហានទី ៣ និងជំហានទី ៤
២. លទ្ធផលនៃដំណើរការកសាងនីមួយៗ

1

## ដំណើរការកសាង CPDP និង CPIP

- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត (CPDP)

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត → ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍ រាជធានី ខេត្ត → ជំហានទី៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត → ជំហានទី៤៖ ការអនុម័ត ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

- កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (CPIP)

ជំហានទី១៖ ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់ CPIP → ជំហានទី២៖ការរៀបចំសេចក្តីព្រាងCPIP → ជំហានទី៣៖ ការអនុម័ត CPIP

2

## នីតិវិធីនៃការកសាងផែនការ៖ ជំហានទី ២

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

↓

**ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

↓

ជំហានទី៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

↓

ជំហានទី៤៖ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

3

## ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

*គោលបំណង*

ដើម្បីផ្សព្វផ្សាយអំពី៖

- គោលការណ៍ណែនាំផ្នែកគោលនយោបាយ
- តម្រូវការ និងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការ
- ឯកសារពាក់ព័ន្ធនានា

4

## ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

*លទ្ធផលរំពឹងទុក*

- អ្នកពាក់ព័ន្ធនានាយល់ដឹងអំពីគោលការណ៍ណែនាំផ្នែកគោលនយោបាយ
- បញ្ជីបូកសរុបបញ្ហា និងតម្រូវការ (តារាង ១.៥ ដល់ ១.៨)
- អ្នកពាក់ព័ន្ធយល់ដឹងពីដំណើរការ និងនីតិវិធីក្នុងការកសាងផែនការ
- អ្នកពាក់ព័ន្ធយល់ដឹងពីតម្រូវការឯកសារនានាដែលចាំបាច់
- ប្រតិទិនការងារសម្រាប់ដំណើរការរៀបចំផែនការអភិវឌ្ឍន៍

5

## ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពីការកសាង ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

*កិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានស្តីពីការកសាងផែនការអភិវឌ្ឍន៍*

- ប្រធានអង្គប្រជុំ៖ អភិបាលរាជធានី ខេត្ត
- សមាសភាព៖ តំណាងក្រុមប្រឹក្សា គណៈអភិបាល ក្រុមការងារកសាងផែនការ និងអ្នកពាក់ព័ន្ធមួយចំនួនទៀត (សូមមើល សេចក្តីណែនាំបច្ចេកទេសផែនការអភិវឌ្ឍន៍ ទំព័រ ២៧)
- របៀបវារៈ ៖ (សូមមើល សេចក្តីណែនាំបច្ចេកទេសផែនការអភិវឌ្ឍន៍ ទំព័រ ២៨)
- ក្រុមការងារកសាងផែនការ ត្រូវចាត់ចែងកិច្ចការចាំបាច់នានាសម្រាប់រៀបចំកិច្ចប្រជុំនេះ

6

## នីតិវិធីនៃការកសាងផែនការ៖ ជំហានទី ៣

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាង ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពី ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**ជំហានទី៣៖ ការកសាងផែនការអភិវឌ្ឍន៍ រាជធានី ខេត្ត**

ជំហានទី៤៖ ការអនុម័តផែនការអភិវឌ្ឍន៍ រាជធានី ខេត្ត

7

## ជំហានទី ៣៖ការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

*គោលបំណង*

ដើម្បីរៀបចំ និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត សម្រាប់ដាក់ជូនគណៈអភិបាលពិនិត្យ និងផ្តល់យោបល់ មុននឹងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

*លទ្ធផលរំពឹងទុក*

សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្តរយៈពេលប្រាំឆ្នាំ

8

## ជំហានទី ៣៖ការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

*ដំណើរការ*

៣-១. ការវិភាគស្ថានភាពរាជធានី ខេត្ត

៣-២. ការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

៣-៣. ការរៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

៣-៤. ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍

៣-៥. កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍

៣-៦. ការពិនិត្យ និងផ្តល់យោបល់របស់ BOG លើសេចក្តីព្រាង

៣-៧. ការពិនិត្យ និងផ្តល់យោបល់របស់ TFC លើសេចក្តីព្រាង

9

## ជំហានទី ៣៖ការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

៣-១. ការវិភាគស្ថានភាពរាជធានី ខេត្ត

*គោលបំណង*

ដើម្បីពិភាក្សា និងរកទស្សនៈឯកភាពអំពីបណ្តាបញ្ហា មូលហេតុ និងដំណោះស្រាយនានាក្នុងអាណត្តិរបស់ក្រុមប្រឹក្សា

*លទ្ធផលរំពឹងទុក*

តារាង ២.១ ដល់ ២.១៤

10

## ជំហានទី ៣៖ការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

៣-១. ការវិភាគស្ថានភាពរាជធានី ខេត្ត (បន្ត)

*ការរៀបចំកិច្ចប្រជុំណែនាំស្តីពីដំណើរការវិភាគស្ថានភាព*

- ប្រធានអង្គប្រជុំ៖ អភិបាលរាជធានី ខេត្ត
- សមាសភាព៖ មន្ត្រីមន្ទីរជំនាញ មន្ត្រីសាលារាជធានី ខេត្ត និងអ្នកពាក់ព័ន្ធមួយចំនួនទៀត
- គោលបំណង៖ ពិភាក្សាបំពេញតារាង ២.១ ដល់ ២.១១
- ឯកសារសំខាន់ៗបម្រើឲ្យការប្រជុំវិភាគ៖ តារាង១.២ ដល់តារាង១.៨ និងឯកសារពាក់ព័ន្ធ

(សូមមើលសេចក្តីណែនាំបច្ចេកទេសផែនការអភិវឌ្ឍន៍ ទំព័រ ៣០)

➢ ក្រុមការងារPWG មន្ទីរផែនការរាជធានី ខេត្ត និងទីចាត់ការផែនការ និងវិនិយោគ ត្រូវចាត់ចែង ដឹកនាំ និងសម្របសម្រួលការពិភាក្សាតាមផ្នែកនីមួយៗ

11

## ជំហានទី ៣៖ការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

៣-១. ការវិភាគស្ថានភាពរាជធានី ខេត្ត (បន្ត)

*នៅក្នុងដំណើរការកិច្ចប្រជុំណែនាំស្តីពីដំណើរការវិភាគស្ថានភាព៖*

- ក្រុមការងារ PWG សំយោគលទ្ធផលទៅក្នុងតារាង ២.១២
- បន្ទាប់មកត្រូវឆ្លង តារាង ២.១២ និងសំយោគទៅជាតារាង ២.១៣ (តារាង ១.៥ + តារាង ២.១២)
  (សូមមើលសេចក្តីណែនាំបច្ចេកទេសផែនការអភិវឌ្ឍន៍ ទំព័រ៣៩)\
- បន្ទាប់មក ក្រុមការងារ PWG ត្រូវគណនាអាទិភាពមធ្យមថ្នាក់រាជធានី ខេត្ត រួចកែសម្រួលជាតារាង ២.១៤

12

## ជំហានទី ៣៖ការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

៣-២. ការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

*គោលបំណង*

ដើម្បីរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

*នីតិវិធី*

ក្រុមការងារ PWG ត្រូវរៀបចំកិច្ចប្រជុំមួយ ដើម្បីពិភាក្សារៀបចំ សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត ជាមួយអ្នកពាក់ព័ន្ធ បន្ទាប់មក ត្រូវដាក់ជូនក្រុមប្រឹក្សា ពិនិត្យ និងអនុម័ត

(សូមមើល សេចក្តីណែនាំបច្ចេកទេសផែនការអភិវឌ្ឍន៍ ទំព័រ ៤១ និង ឯកសារបទបង្ហាញ ផ្នែកទី៨ ៩ ១០ ១១)

13

# តារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

▪បន្ទាប់ពីការវិភាគស្ថានភាព ក្រុមការងារកសាងផែនការត្រូវរៀបចំកិច្ចប្រជុំ ដើម្បីពិភាក្សា និងរៀបចំចក្ខុវិស័យអភិវឌ្ឍន៍ គោលបំណងអភិវឌ្ឍន៍ សូចនាករ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍។ ក្នុងការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុមការងារកសាងផែនការ ត្រូវអញ្ជើញតំណាងក្រុមប្រឹក្សារាជធានី ខេត្ត និង គណៈកម្មាធិការពាក់ព័ន្ធនានារបស់ក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធសំខាន់ៗ ដែលមានចំណេះដឹង និងបទពិសោធន៍ក្នុងការងារនេះ មកចូលរួមផ្តល់យោបល់។

▪គណៈអភិបាលរាជធានី ខេត្ត ត្រូវផ្ញើរក្របខ័ណ្ឌអភិវឌ្ឍន៍ដែលបានរៀបចំជូន ក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័ត ដើម្បីជាមូលដ្ឋានសម្រាប់ គណៈអភិបាលរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាពិសេស ការរៀបចំកម្មវិធី វិនិយោគបីឆ្នាំរំកិលលើកទី ១។

14

# តារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត(បន្ត)

| ចក្ខុវិស័យ ៖ | | | | |
|---|---|---|---|---|
| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
| | ឯកតា | ២០០៩ | ២០១៤ | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | |
| ១.១. គោលដៅ ៖ | | | | |
| ១.១.១. គោលបំណង ៖ | | | | |
| ១.១.២. គោលបំណង ៖ | | | | |
| ១.២. គោលដៅ ៖ | | | | |
| ១.២.១. គោលបំណង ៖ | | | | |
| ១.២.២. គោលបំណង ៖ | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | |
| ២.១. គោលដៅ ៖ | | | | |
| ២.១.១. គោលបំណង ៖ | | | | |
| ២.១.២. គោលបំណង ៖ | | | | |
| ៣. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | | | | |
| ៣.១. គោលដៅ ៖ | | | | |
| ៣.១.១. គោលបំណង ៖ | | | | |
| ៣.១.២. គោលបំណង ៖ | | | | |
| ៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | |
| ៤.១. គោលដៅ ៖ | | | | |
| ៤.១.១. គោលបំណង ៖ | | | | |
| ៤.១.២. គោលបំណង ៖ | | | | |

Table_Development Framework_K.docx

15

## តារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត(បន្ត)

| ពាក្យបច្ចេកទេស | និយមន័យ |
|---|---|
| ចក្ខុវិស័យ | ស្ថានភាពអនាគតដែលចង់សម្រេចបានរបស់ស្ថាប័នមួយ ឬសហគ្រាសមួយ នូវអ្វីដែលស្ថាប័នទាំងនោះអនុវត្ត។ ឧទា. ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ជនក្រីក្រ អាចមានប្រយោគចក្ខុវិស័យដែលអាន ថា -ពិភពលោកមួយដែលគ្មានភាពក្រីក្រ-។ |
| គោលដៅ និងគោលបំណង | ប្រយោគដែលមានពេលវេលាកំណត់ជាក់លាក់ លើលទ្ធផលចង់សម្រេចបាននាពេលអនាគត និងទូទៅនៃលទ្ធផលចង់សម្រេច បាននាពេលអនាគត។<br><br>សម្គាល់៖ និយមន័យភាគច្រើនសំដៅទៅលើគោលដៅ ឬគោលបំណង (ជួនកាលអាចផ្លាស់ប្តូរគ្នាបាន)។ ក្នុងករណីណែនាំ គោលដៅ និងគោលបំណងត្រូវបានសន្មតថា មានទំនាក់ទំនងបែបឋានានុក្រម (គោលដៅជាលទ្ធផល និង គោលបំណងជាមធ្យោបាយ)។ |

16

## តារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត(បន្ត)

| | |
|---|---|
| សូចនាករ | សូចនាករគួរតែបង្ហាញពីកម្រិតនៃសមិទ្ធិផលសម្រាប់គោលដៅ និងគោលបំណង។ សូចនាករគួរតែបញ្ចូលនូវព័ត៌មានដូចខាងក្រោម៖<br><br>១) វត្ថុ (អ្វី?)<br>២) អ្នកទទួលផល (ដើម្បីអ្នកណា?)<br>៣) បរិមាណ (ចំនួនប៉ុន្មាន ?)<br>៤) គុណភាព (ល្អប៉ុណ្ណា)<br>៥) កាលបរិច្ឆេទ (ត្រឹមពេលណា?)<br>៦) ទីកន្លែង (នៅកន្លែងណា?) |
| យុទ្ធសាស្ត្រ | ការបូកសរុបនៃលទ្ធផល(គោលដៅ) ដែលស្ថាប័នកំពុងប្រឹងប្រែង និងមធ្យោបាយ (គោលនយោបាយ) ដែលចង់សម្រេចបាន។ |

17

## ជំហានទី ៣៖ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

៣-៣. ការរៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍

*គោលបំណង*

ដើម្បីរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត CPDP

*លទ្ធផល*

- សេចក្តីព្រាងយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍

18

## ជំហានទី ៣៖ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

៣-៣. ការរៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍(បន្ត)

ក្រុមការងារកសាងផែនការ ត្រូវពិភាក្សា និងរៀបចំយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត ផែនការអភិវឌ្ឍន៍ ដោយផ្តោតលើចំណុចសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

- យន្តការសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការ
- សូចនាករសំខាន់ៗ សម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការ
- វិធីសាស្ត្រតាមដាន និងវាយតម្លៃការអនុវត្តផែនការ
- ពេលវេលាសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការ
- ប្រព័ន្ធរៀបចំរបាយការណ៍។

19

## ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ(១)

- PWG ត្រូវណែនាំ ឲ្យបំពេញតារាងដូចខាងក្រោម ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្ត ផែនការ។

## ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ(២)

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | មន្ទីរ អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | |
| គោលដៅ ១ | | | | | | | | | |
| សូចនាករ១.១ | | | | | | | | | |
| សូចនាករ១.២ | | | | | | | | | |
| គោលដៅ ២ | | | | | | | | | |
| សូចនាករ២.១ | | | | | | | | | |
| សូចនាករ២.២ | | | | | | | | | |
| សូចនាករ២.៣ | | | | | | | | | |
| សូចនាករ២.៤ | | | | | | | | | |
| ២.ផ្នែកសង្គមកិច្ច | | | | | | | | | |
| គោលដៅ ៣ | | | | | | | | | |
| សូចនាករ៣.១ | | | | | | | | | |
| សូចនាករ៣.២ | | | | | | | | | |

21

**ជំហានទី ៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

## ៣-៤. ការសរសេរសេចក្តីព្រាងផែនការអភិវឌ្ឍន៍

*គោលបំណង*

រៀបចំសេចក្តីព្រាង CPDP

*សមាសភាព*

ក្រុមការងារកសាងផែនការ (PWG)

*លទ្ធផល*

សេចក្តីព្រាង CPDP

## ទម្រង់សៀវភៅ CPDP

- សេចក្តីសម្រេចស្តីពីដាក់ឲ្យប្រើប្រាស់ CPDP
- អារម្ភកថា
- សេចក្តីផ្តើម
- ផែនទីរាជធានី ខេត្ត
- **ជំពូកទី១៖ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច**
- ១.១ សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច
- ១.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម
  - ១.២.១ ស្ថានភាពសេដ្ឋកិច្ច
  - ១.២.២ ស្ថានភាពសង្គមកិច្ច
  - ១.២.៣ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន
  - ១.២.៤ ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ
  - ១.២.៥ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ
- **ជំពូកទី២៖ ក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានីខេត្ត**
- ២.១ ចក្ខុវិស័យអភិវឌ្ឍន៍
- ២.២ គោលដៅអភិវឌ្ឍន៍
- ២.៣ គោលបំណងអភិវឌ្ឍន៍
- ២.៤ យុទ្ធសាស្រ្តអភិវឌ្ឍន៍
  - ២.៤.១ យុទ្ធសាស្រ្តអភិវឌ្ឍន៍សេដ្ឋកិច្ច
  - ២.៤.២ យុទ្ធសាស្រ្តអភិវឌ្ឍន៍សង្គម
  - ២.៤.៣ យុទ្ធសាស្រ្តប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន
  - ២.៤.៤ យុទ្ធសាស្រ្តគ្រប់គ្រងគ្រោះមហន្តរាយ និង ការប្រែប្រួលអាកាសធាតុ
  - ២.៤.៥ យុទ្ធសាស្រ្តគ្រប់គ្រងរដ្ឋបាល និង សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ
- ២.៥ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- **ជំពូកទី៣៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍**
- ឧបសម្ព័ន្ធ

## ជំហានទី ៣៖ ការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

៣-៥. កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបឋមស្តីពីផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

*គោលបំណង*

-ដើម្បីបង្ហាញខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងបឋមស្តីពី CPDP

-ដើម្បីប្រមូលមតិយោបល់ និងអនុសាសន៍ ដើម្បីកែលម្អសេចក្តីព្រាងបឋមស្តីពី CPD

24

## ជំហានទី ៣៖ ការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

៣-៥. កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបឋមស្តីពីផែនការអភិវឌ្ឍន៍រាជធានី ខេត្ត (បន្ត)

*សមាសភាព*

- ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត (BOG)
- ក្រុមការងាររៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត (PWG)
- តំណាងក្រុមប្រឹក្សាគ្រប់ក្រុង ស្រុក ខណ្ឌ
- តំណាងក្រុមប្រឹក្សាគ្រប់សង្កាត់ ក្នុងរាជធានី ខេត្ត
- សមាជិក TFC និងគណៈកម្មាធិការពាក់ព័ន្ធផ្សេងទៀត
- តំណាងអង្គការសង្គមស៊ីវិលពាក់ព័ន្ធក្នុងរាជធានី ខេត្ត
- អ្នកពាក់ព័ន្ធដទៃទៀតទៅតាមការចាំបាច់។

***លទ្ធផលរំពឹងទុក***

- កែលម្អសេចក្តីព្រាងបឋមស្តីពី CPDP

25

**ជំហានទី ៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

៣-៥. កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបឋមស្តីពីផែនការអភិវឌ្ឍន៍រាជធានី ខេត្ត (បន្ត)

*ការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបឋមស្តីពីផែនការអភិវឌ្ឍន៍*

- ប្រធានអង្គប្រជុំ៖ អភិបាលរាជធានី ខេត្ត
- ដំណើរការ៖
  - បទបង្ហាញអំពីខ្លឹមសារនៃសេចក្តីព្រាងបឋម
  - ចែកក្រុមពិភាក្សា
  - បង្ហាញលទ្ធផលពិភាក្សាក្នុងអង្គប្រជុំ
- អ្នករៀបចំ៖ ក្រុមការងារកសាងផែនការ

(សូមមើល សេចក្តីណែនាំបច្ចេកទេសផែនការអភិវឌ្ឍន៍ ទំព័រ ៤២)

26

**ជំហានទី ៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

៣-៦. ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាង CPDP

*គោលបំណង*

កែសម្រួលសេចក្តីព្រាង CPDP

*សមាសភាព*

- ក្រុមការងារកសាងផែនការ (PWG)
- គណៈអភិបាលរាជធានី ខេត្ត

*លទ្ធផល*

- កែសម្រួលសេចក្តីព្រាង CPDP

27

## ជំហានទី ៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

៣-៦. ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាង CPDP (បន្ត)

*នីតិវិធី*

- គណៈអភិបាល ត្រូវរៀបចំកិច្ចប្រជុំមួយ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាង CPDP

→ក្រុមការងារកសាងផែនការ កែសម្រួលសេចក្តីព្រាងCPDP ស្របតាមមតិយោបល់របស់ គណៈអភិបាល

→ គណៈអភិបាល ត្រូវបញ្ជូនសេចក្តីព្រាង CPDP នេះទៅគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីពិនិត្យ និង ផ្តល់យោបល់

## ជំហានទី ៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

៣-៧ ការពិនិត្យ និងផ្តល់យោបល់ដោយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស លើសេចក្តីព្រាងCPDP

*គោលបំណង*

កែសម្រួលសេចក្តីព្រាង CPDP

*សមាសភាព*

- ក្រុមការងារកសាងផែនការ (PWG)
- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស (TFC)
- គណៈអភិបាល

*លទ្ធផល*

- កែសម្រួលសេចក្តីព្រាង CPDP

## ជំហានទី ៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

៣-៧ ការពិនិត្យ និងផ្តល់យោបល់ដោយ គណៈកម្មាធិការសម្រប សម្រួលបច្ចេកទេស លើសេចក្តីព្រាងCPDP

*នីតិវិធី*

-TFC រៀបចំកិច្ចប្រជុំមួយ ដើម្បី ពិនិត្យ និងផ្តល់យោបល់

→BOG ត្រូវណែនាំឲ្យក្រុមការងារកសាងផែនការ កែសម្រួល បញ្ចប់ តាមមតិយោបល់របស់ TFC

→BOG ដាក់ជូន សេចក្តីព្រាង CPDP នេះទៅក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីពិនិត្យ និងអនុម័ត

## នីតិវិធីនៃការកសាងផែនការ៖ ជំហានទី ៤

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាង ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

↓

ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពី ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

↓

ជំហានទី៣៖ ការកសាងផែនការអភិវឌ្ឍន៍ រាជធានី ខេត្ត

↓

**ជំហានទី៤៖ ការអនុម័តផែនការអភិវឌ្ឍន៍ រាជធានី ខេត្ត**

**ជំហានទី ៤៖ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

៤-១. ការងារមុនសម័យប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

↓

៤-២. ការប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

↓

៤-៣. ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

32

**ជំហានទី ៤៖ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

៤-១. ការងារមុនសម័យប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

ក្រុមការងារកសាងផែនការ សហការជាមួយទីចាត់ការផែនការ និងវិនិយោគ និងទីចាត់ការរដ្ឋបាល ត្រូវ៖

-រៀបចំរបៀបវារៈ

-រៀបចំសេចក្តីថ្លែងហេតុ

-រៀបចំឯកសារបទបង្ហាញ

-រៀបចំលិខិតអញ្ជើញ

-កិច្ចការចាំបាច់ផ្សេងៗទៀត តាមការណែនាំរបស់អភិបាលរាជធានី ខេត្ត

33

**ជំហានទី ៤ ៖ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

៤-២. ការប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

ក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំមួយ តាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុង របស់ខ្លួន តាមរបៀបវារៈដូចតទៅ៖

១)-សេចក្តីថ្លែងហេតុ និងបទបង្ហាញអំពីសេចក្តីព្រាង CPDP

២)-ការពិនិត្យ ពិភាក្សា និងអនុម័ត សេចក្តីព្រាង CPDP

៣)-ផ្សេងៗ

34

**ជំហានទី ៤ ៖ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

៤-៣. ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

▪<u>ការផ្តល់អនុលោមភាព</u>

-BOG កែសម្រួលសេចក្តីព្រាង CPDP តាមមតិយោបល់របស់ក្រុមប្រឹក្សា

→អភិបាលរាជធានី ខេត្ត ត្រូវផ្ញើរជូនសេចក្តីព្រាង CPDP នេះ ទៅលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីសុំផ្តល់អនុលោមភាព

→BOG កែសម្រួលសេចក្តីព្រាង CPDP តាមមតិយោបល់ទទួលបាន (ក្នុងរយៈពេល ៣០ថ្ងៃ បើគ្មានការឆ្លើយតបទេ សេចក្តីព្រាង CPDP ត្រូវចាត់ទុកថា បានទទួលអនុលោមភាពពី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ)

→ដាក់ជូនក្រុមប្រឹក្សាពិនិត្យ អនុម័ត តាមរយៈកិច្ចប្រជុំ

35

**ជំហានទី ៤ ៖ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

៤-៣. ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត (បន្ត)

- <u>ការចេញសេចក្តីសម្រេច</u>
  - BOG ត្រូវរៀបចំ សេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់ CPDP ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខា
- <u>ការបោះពុម្ពសៀវភៅ CPDP</u>
  - BOG ត្រូវរៀបចំបោះពុម្ពសៀវភៅ CPDP ដើម្បីបែងចែកផ្សព្វផ្សាយ

36

**ជំហានទី ៤ ៖ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

៤-៣. ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត (បន្ត)

- <u>ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ</u>
  - ក្រុមប្រឹក្សាត្រូវណែនាំឲ្យ BOG ចាត់ចែងការអនុវត្ត CPDP ដោយមានតម្លាភាព មានគណនេយ្យភាព មានការចូលរួម និងមានប្រសិទ្ធភាព។
  - ក្រុមប្រឹក្សា ត្រូវទទួលខុសត្រូវក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជារៀងរាល់ឆ្នាំ។

**ជំហានទី ៤៖ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

៤-៣. ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត (បន្ត)

- នៅចុងឆ្នាំនីមួយៗ គណៈអភិបាលត្រូវរៀបចំ និងដាក់ជូនរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។
- ក្រៅពីរបាយការណ៍ប្រចាំឆ្នាំ គណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ផែនការអភិវឌ្ឍន៍ និងរបាយការណ៍ផ្សេងទៀត ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាជាប្រចាំ។
- ក្នុងករណីចាំបាច់ ក្រុមប្រឹក្សារាជធានី ខេត្ត អាចធ្វើការកែតម្រូវផែនការអភិវឌ្ឍន៍ ក្នុងអំឡុងពេលនៃការអនុវត្តផែនការនេះ ។

**សូមអរគុណ!**

## ឯកសារចែកជូនផ្នែកទី៤៖ បូកសរុបតារាង៖ តារាង ១.១ តារាង ១.២ និងតារាង ១.៣

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាង
ផែនការអភិវឌ្ឍន៍ រាជធានី ខេត្ត
១-១ កិច្ចប្រជុំណែនាំ

### ការវិភាគបញ្ហា (ដើមឈើបញ្ហា)




បញ្ហាយេនឌ័រដែលមើលរំលង៖

១) ស្ត្រីហាក់មានឱកាសតិចក្នុងការទទួលព័ត៌មានអំពីជំងឺសត្វ

### ការវិភាគដំណោះស្រាយ (ដើមឈើដំណោះស្រាយ)




គោលបំណងយេនឌ័រ៖

១) ស្ត្រីមានឱកាសស្មើគ្នាក្នុងការទទួលព័ត៌មានអំពីជំងឺសត្វ

### តារាង ១.១ ដល់តារាង ១.៣

| វិស័យ និងសកម្មភាព ឬសេវា | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព |
|---|---|---|---|---|---|
| **១. ផ្នែកសង្គមកិច្ច** | | | | | |
| (វិស័យ សុខាភិបាល)<br>សកម្មភាព៖<br>(ឃ)<br>សត្វពាហនៈនៅក្នុងភូមិមានសុខភាពល្អ ។ | (ក)<br>សត្វពាហនៈនៅក្នុងភូមិមានជំងឺអុតក្តាមចម្លែករហូតងាប់ ។ | (ខ១)<br>១.ប្រជាពលរដ្ឋខ្វះចំណេះដឹងអំពីជំងឺអុតក្តាម។<br>(ខ២)<br>២.ការឆ្លើយតបរបស់ឃុំមិនទាន់ពេលវេលា<br>(ខ៣)<br>៣.មន្ត្រីបសុពេទ្យផ្តល់សេវាមិនបានល្អ<br>(ខ៤)<br>៤.ប្រជាពលរដ្ឋមិនអាចអញ្ជើញពេទ្យសត្វបាន។ | (ង១)<br>១-១ ផ្សព្វផ្សាយអំពីជំងឺសត្វដល់ប្រជាពលរដ្ឋ<br>(ង២)<br>២-១ បណ្តុះបណ្តាលឃុំអំពីអភិបាលកិច្ចល្អ<br>(ង៣)<br>៣-១ ពង្រឹងរបៀបរបបការងាររបស់មន្ទីរ<br>(ង៤)<br>៤-២ បង្កើតពេទ្យសត្វសហគមន៍សម្រាប់ប្រជាពលរដ្ឋ | (គ)<br>១. ស្ត្រីហាក់មានឱកាសតិចក្នុងការទទួលព័ត៌មានអំពីជំងឺសត្វ | |

# ឯកសារចែកជូនផ្នែកទី៤៖ បូកសរុបតារាង៖ តារាង ១.១ តារាង ១.២ និងតារាង ១.៣ ទៅតារាង ១.៥ តារាង ១.៦ និងតារាង ១.៧

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ រាជធានី ខេត្ត

១-២ ការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា រាជធានី ខេត្ត

**តារាង ១.១ / ស្រុក ក**

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព |
|---|---|---|---|---|---|
| ១. ផ្នែកសង្គមកិច្ច | | | | | |
| (វិស័យកសិកម្ម) សកម្មភាព៖ សត្វពាហនៈ: នៅក្នុងភូមិមានសុខភាពល្អ | សត្វពាហនៈ: នៅក្នុងភូមិមានជំងឺអុតក្តាមចម្លែកឈឺរហូតដល់ងាប់។ | ១. ប្រជាពលរដ្ឋខ្វះ: ចំណេះដឹងអំពីជំងឺអុតក្តាម។ | ១.១ ផ្សព្វផ្សាយអំពីជំងឺសត្វដល់ប្រជាពលរដ្ឋតាមរយៈការបណ្តុះបណ្តាល | ១. ស្ត្រីហាក់មានការសកិចក្នុងការទទួលព័ត៌មានអំពីជំងឺសត្វ | ខ្ពស់ |
| | | ២. ការឆ្លើយតបរបស់មេឃុំមិនទាន់ពេលវេលា។ | ២.១ បណ្តុះបណ្តាលឃុំអំពីអភិបាលកិច្ចល្អ | | ទាប |
| | | ៣. មន្ត្រីបសុពេទ្យផ្តល់សេវាមិនបានល្អ | ៣.១ ពង្រឹងរបៀបរបបការងាររបស់មន្ទីរ | | មធ្យម |
| | | ៤. ប្រជាពលរដ្ឋមិនអាចអញ្ជើញពេទ្យសត្វបាន | ៤.១ បង្កើតពេទ្យសត្វសហគមន៍សម្រាប់ប្រជាពលរដ្ឋ | | ខ្ពស់ |

**តារាង ១.១ / ស្រុក ខ**

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព |
|---|---|---|---|---|---|
| **១. ផ្នែកសង្គមកិច្ច** | | | | | |
| (វិស័យកសិកម្ម) សកម្មភាព៖ សត្វពាហនៈនៅក្នុងភូមិមានសុខភាពល្អ | សត្វពាហនៈ: នៅក្នុងភូមិមានជំងឺអុតក្តាមចម្លែកឈឺរហូតដល់ងាប់។ | ១. ប្រជាពលរដ្ឋខ្វះ: ចំណេះដឹងអំពីជំងឺអុតក្តាម | ១.១ ផ្សព្វផ្សាយអំពីជំងឺសត្វដល់ប្រជាពលរដ្ឋតាមរយៈវិទ្យុ | ១. ស្ត្រីហាក់មានឱកាសតិចក្នុងការទទួលព័ត៌មានអំពីជំងឺសត្វ | ខ្ពស់ |
| | | ២. ការឆ្លើយតបរបស់មេឃុំមិនទាន់ពេលវេលា | ២.១ បណ្តុះបណ្តាលឃុំអំពីអភិបាលកិច្ចល្អ | | ទាប |
| | | ៣. មន្ត្រីបសុពេទ្យផ្តល់សេវាមិនបានល្អ | ៣.១ ពង្រឹងរបៀបរបបការងាររបស់មន្ទីរ | | មធ្យម |
| | | ៤. ប្រជាពលរដ្ឋមិនអាចអញ្ជើញពេទ្យសត្វបាន | ៤.១ បង្កើតពេទ្យសត្វសហគមន៍សម្រាប់ប្រជាពលរដ្ឋ | | មធ្យម |

**តារាង ១.៥**

| វិស័យ និងសកម្មភាព | ដំណោះស្រាយ | អាទិភាព ក្រុង ស្រុក ខណ្ឌ | | | អាទិភាពជាមធ្យម |
|---|---|---|---|---|---|
| | | ស្រុក ក | ស្រុក ខ | ស្រុក គ | |
| វិស័យកសិកម្ម សកម្មភាព៖ | ១. ផ្សព្វផ្សាយអំពីជំងឺសត្វដល់ប្រជាពលរដ្ឋតាមរយៈវិទ្យុ | ខ្ពស់ | | | មធ្យម |
| | ២.បណ្តុះបណ្តាលឃុំអំពីអភិបាលកិច្ចល្អ | ទាប | ទាប | | ទាប |
| សត្វពាហនៈនៅក្នុងភូមិមានសុខភាពល្អ | ៣.ពង្រឹងរបៀបរបបការងាររបស់មន្ទីរ | មធ្យម | មធ្យម | | ខ្ពស់ |
| | ៤.បង្កើតពេទ្យសត្វសហគមន៍សម្រាប់ប្រជាពលរដ្ឋ | ខ្ពស់ | មធ្យម | | ខ្ពស់ |
| | ៥. ផ្សព្វផ្សាយអំពីជំងឺសត្វដល់ប្រជាពលរដ្ឋតាមរយៈការបណ្តុះបណ្តាល | | ខ្ពស់ | | មធ្យម |

កំណត់សម្គាល់៖

១.បំលែងជាពិន្ទុអាទិភាព ដោយ ខ្ពស់=៣ មធ្យម=២ ទាប=១

២.រកពិន្ទុអាទិភាពមធ្យមនៃដំណោះស្រាយ = ផលបូកពិន្ទុអាទិភាពសរុប / ចំនួនអង្គភាពសរុប

៣.តំរៀបពិន្ទុអាទិភាពមធ្យមពីខ្ពស់មកទាប

៤.កំណត់អាទិភាពមួយភាគបី ដូចខាងក្រោម៖

ខ្ពស់=១/៣ ដំបូង មធ្យម=១/៣ បន្ទាប់ ទាប=១/៣ចុងក្រោយ

...ចែកជូន

**ស្រុក ខ**

**ការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ ១ ៖ បញ្ហាសុខភាពស្ត្រី (សូមចម្លងពីផ្នែកទី៣)**

# ការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ ២ ៖ បញ្ហាកសិកម្ម

## ការវិភាគបញ្ហា




## ការវិភាគដំណោះស្រាយ



## ការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ ៣ ៖ បញ្ហាអប់រំ

### ការវិភាគបញ្ហា

បញ្ហាយេនឌ័រដែលមើលរំលង
- កុមារាត្រូវបានផ្តល់អាទិភាពឲ្យចូលរៀននៅសាលា។

បញ្ហាយេនឌ័រដែលមើលរំលង
- កុមារីត្រូវបានរំពឹងជាកម្លាំងការងារគ្រួសារចាប់ពីនៅក្មេង

សិស្សជាច្រើនបោះបង់ការសិក្សានៅថ្នាក់ទី៦។

- ឪពុកម្តាយមានការលំបាកក្នុងការរ៉ាប់រងនូវរាល់ការចំណាយ។
  - ឪពុកម្តាយត្រូវចំណាយបន្ថែមក្រៅផ្លូវការដល់សាលា។
  - គ្រួសារនីមួយៗមានកូនជាច្រើនដល់អាយុចូលរៀន។
- កុមាររវល់ធ្វើការងារផ្ទះ។
  - កុមារត្រូវបានរំពឹងទុកជាកម្លាំងការងារសម្រាប់កិច្ចការផ្ទះ។
  - សាលារៀនមិនទាក់ទាញសិស្សឲ្យចូលរៀន។

### ការវិភាគរកដំណោះស្រាយ

តម្រូវការយេនឌ័រ
- កុមារានិងកុមារីមានសិទ្ធិស្មើគ្នាក្នុងការចូលរៀន។

តម្រូវការយេនឌ័រ
- កុមារីមានអាទិភាព ក្នុងការចូលរៀន។

សិស្សភាគច្រើនចូលរៀនដល់ថ្នាក់ទី ៦។

- ឪពុកម្តាយអាចរ៉ាប់រងរាល់ការចំណាយ។
  - ឪពុកម្តាយបង់តែថ្លៃចំណាយផ្លូវការដល់សាលា។
  - គ្រួសារនីមួយៗមានកូនចំនួនសមស្រប។
- ការចូលរៀនជាអាទិភាពទី ១ សម្រាប់កុមារ។
  - កុមារអាចធ្វើការសម្រាប់គ្រួសារក្រោយពេលសិក្សា។
  - សាលាទាក់ទាញកុមារចូលរៀន។

## ផ្នែកទី៤- ឯកសារចែកជូន

**ស្រុក គ**

## ការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ ១ ៖ បញ្ហាកសិកម្ម

### ការវិភាគបញ្ហា




### ការវិភាគដំណោះស្រាយ



# ការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ ២ ៖ បញ្ហាសុខភាព

## ការវិភាគបញ្ហា




## ការវិភាគដំណោះស្រាយ



## ការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ ៣ ៖ បញ្ហាអប់រំ

### ការវិភាគបញ្ហា




### ការវិភាគរកដំណោះស្រាយ



# ផ្នែកទី៤- ឯកសារចែកជូន

**ស្រុក យ**

## ការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ ១ ៖ បញ្ហាកសិកម្ម

### ការវិភាគបញ្ហា




### ការវិភាគដំណោះស្រាយ



# ការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ ២ ៖ បញ្ហាកសិកម្ម

## ការវិភាគបញ្ហា




## ការវិភាគដំណោះស្រាយ



## ការវិភាគបញ្ហា/ការវិភាគដំណោះស្រាយ ៣ ៖ បញ្ហាអប់រំ

### ការវិភាគបញ្ហា




### ការវិភាគរកដំណោះស្រាយ



# <u>ផ្នែកទី ៨</u>

# លំហាត់៖ ការបំពេញតារាងនានា

# សម្រាប់ CPDP

គ.ជ.អ.ប
NCDD

JICA

# ផ្នែកទី ៨

## លំហាត់៖ ការបំពេញតារាងនានា

## សម្រាប់ CPDP

គម្រោងសម្រាប់កិច្ចអភិវឌ្ឍសមត្ថភាព
ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ
នៅថ្នាក់រាជធានី ខេត្ត (PILAC2)

# គោលបំណង និងមាតិកា

គោលបំណងនៃផ្នែកទី ៨៖

សិក្ខាកាមមានសមត្ថភាពបំពេញតារាងសម្រាប់ CPDP

មាតិកា៖ ១.បទបង្ហាញស្តីពីវិធីបំពេញតារាង
២.លំហាត់

# ដំណើរការកសាង CPDP និង CPIP

- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត (CPDP)

ជំហានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត → ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត → ជំហានទី៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត → ជំហានទី៤: ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

- កម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត (CPIP)

ជំហានទី១៖ ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់ CPIP → ជំហានទី២៖ ការរៀបចំសេចក្តីព្រាង CPIP → ជំហានទី៣៖ ការអនុម័ត CPIP

2

ជំហានទី ៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

## ៣-១. ការវិភាគស្ថានភាពរាជធានី ខេត្ត

*គោលបំណង*

ដើម្បីពិភាក្សា និងរកទស្សនៈឯកភាពលើបញ្ហានានា មូលហេតុនៃបញ្ហា និងដំណោះស្រាយក្នុងវិស័យនានានៃរាជធានី ខេត្ត

3

## ជំហានទី ៣៖ ការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

### ៣-១. ការវិភាគស្ថានភាពរាជធានី ខេត្ត (បន្ត)

*សមាសភាព*

- មន្ត្រីបច្ចេកទេសពីមន្ទីរ អង្គភាពនានាដែលពាក់ព័ន្ធនឹងផ្នែកនីមួយៗ
- មន្ត្រីពាក់ព័ន្ធនានានៃទីចាត់ការសាលារាជធានី ខេត្ត
- សមាជិកនៃគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- អ្នកពាក់ព័ន្ធផ្សេងៗទៀតដូចជា តំណាងក្រុមប្រឹក្សា នៃរដ្ឋបាលប្រភេទរួមគ្នា និងប្រភេទផ្សេងគ្នា។
- តំណាងអង្គការសង្គមស៊ីវិល និងវិស័យឯកជន
- ក្រុមការងាររកសាងផែនការ (PWG) (អ្នកសម្របសម្រួល)
- មន្ទីរផែនការរាជធានី ខេត្ត (អ្នកសម្របសម្រួល)
- ទីចាត់ការផែនការ និងវិនិយោគ (អ្នកសម្របសម្រួល)

*លទ្ធផល*

- តារាង ២.១ ដល់តារាង ២.១៤

4

## ៣-១ ការវិភាគស្ថានភាព សម្រាប់តារាង២.១ ដល់តារាង២.១១

- ជាបឋម PWG ត្រូវណែនាំពីវិធីរៀបចំការវិភាគស្ថានភាពនៃផ្នែកនីមួយៗ នៅក្នុងកិច្ចប្រជុំណែនាំ
- បន្ទាប់មក អ្នកពាក់ព័ន្ធត្រូវបែងចែកទៅជាបួន (៤)ក្រុម ហើយក្រុមនីមួយៗ ត្រូវបំពេញនូវតារាងដែលខ្លួនទទួលខុសត្រូវ

| | |
|---|---|
| ▪ផ្នែកសេដ្ឋកិច្ច ➔ | តារាង២.១ |
| ▪ផ្នែកសង្គមកិច្ច ➔ | តារាង២.២ តារាង២.៣ តារាង២.៤ |
| ▪ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន មហន្តរាយ ➔ | តារាង២.៥ តារាង២.៦ តារាង២.៧ តារាង២.៨ និងតារាង២.៩ |
| ▪ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ➔ | តារាង២.១០ និងតារាង២.១១ |

5

## ផ្នែកសេដ្ឋកិច្ច ៖ តារាង២.១៖ ការវិភាគផ្នែកសេដ្ឋកិច្ច

១. ជ្រើសរើស វិស័យ និងសកម្មភាពសំខាន់ៗ ក្នុងផ្នែកសេដ្ឋកិច្ច ដែលអ្នកពាក់ព័ន្ធយល់ថាមានសារៈសំខាន់ និងចង់លើកចំណុចទាំងនោះមកដោះស្រាយ ក្នុងអំឡុង ៥ឆ្នាំខាងមុខ។ វិស័យ និងសកម្មភាពសំខាន់ៗ គួរតែជ្រើសរើស ដោយផ្អែកតាមលក្ខខ័ណ្ឌ នៃកម្រិតចំណូល ផលិតផល ចំនួនប្រជាជនដែលធ្វើការ និងតំបន់ភូមិសាស្ត្រក្នុងវិស័យជាក់លាក់មួយ។

២. "សក្តានុពល" កត្តាសក្តានុពល ដែលគួរឲ្យកត់សម្គាល់មួយចំនួន (មានលក្ខណៈវិជ្ជមាន) អាចត្រូវលើកយកមកពណ៌នា។

៣. "ទំហំបញ្ហា" ត្រូវគិតជាចំនួន (ប្រសិនបើមានលទ្ធភាព) ដូចជាចំនួនប្រជាជន ដែលទទួលផលប៉ះពាល់ ដោយបញ្ហាជាក់លាក់ណាមួយ។

## ផ្នែកសេដ្ឋកិច្ច ៖ តារាង២.១៖ ការវិភាគផ្នែកសេដ្ឋកិច្ច(បន្ត)

៤. បំពេញជួរឈរនៃ "មូលហេតុ" និង "ដំណោះស្រាយ" ដោយប្រើប្រាស់វិធីសាស្ត្រការវិភាគបញ្ហា និងការវិភាគរកដំណោះស្រាយ។

| វិស័យ និង សកម្មភាពចម្បងៗ | សក្តានុពល (ភាពខ្លាំង) | បញ្ហា (ភាពខ្សោយ) | ទំហំបញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|---|---|---|
| កសិកម្ម | | | | | | |
| ការធ្វើស្រែ | នាំស្រូវចេញទៅក្រៅប្រទេស | - ទិន្នផលទាប<br>- ការកិនស្រូវមានគុណភាពទាប | ៥០០០ គ្រួសារធ្វើស្រែ | - ខ្វះធនធានផ្នែកកសិកម្ម<br>- រោងម៉ាស៊ីនកិនស្រូវមិនគ្រប់គ្រាន់ | - ណែនាំបច្ចេកទេសសមស្រប<br>- លើកកម្ពស់ការវិនិយោគផ្នែកឯកជន ក្នុងការកិនស្រូវ | |

## ផ្នែកសង្គមកិច្ច ៖ តារាង២.២៖ ការវិភាគផ្នែកសង្គមកិច្ច

១. ជ្រើសរើស វិស័យ និងសកម្មភាពសំខាន់ៗ ក្នុងផ្នែកសង្គមកិច្ច ដែលអ្នកពាក់ព័ន្ធយល់ថាមានសារៈសំខាន់ និងចង់លើកចំណុចទាំងនោះមកដោះស្រាយ ក្នុងអំឡុង ៥ឆ្នាំខាងមុខ។ វិស័យ និងសកម្មភាពសំខាន់ៗ គួរតែជ្រើសរើស ដោយផ្អែកតាមលក្ខខណ្ឌ នៃកម្រិតចំណូលផលិតផល ចំនួនប្រជាជនដែលធ្វើការ និងតំបន់ ភូមិសាស្ត្រ ក្នុងវិស័យជាក់លាក់មួយ។

២. "**សក្តានុពល**" កត្តាសក្តានុពល ដែលគួរឲ្យកត់សម្គាល់មួយចំនួន (មានលក្ខណៈវិជ្ជមាន) អាចត្រូវលើកយកមកពណ៌នា។

៣. "**ទំហំបញ្ហា**" ត្រូវគិតជាចំនួន (ប្រសិនបើមានលទ្ធភាព) ដូចជាចំនួនប្រជាជន ដែលទទួលផលប៉ះពាល់ ដោយបញ្ហាជាក់លាក់ណាមួយ។

៨

## ផ្នែកសង្គមកិច្ច(១) ៖ តារាង២.២៖ការវិភាគការងារសង្គមកិច្ច(បន្ត)

៤. បំពេញជួរឈរនៃ "មូលហេតុ" និង "ដំណោះស្រាយ" ដោយប្រើប្រាស់វិធីសាស្ត្រការវិភាគបញ្ហា និងការវិភាគរកដំណោះស្រាយ។

| វិស័យ និង សកម្មភាព ឬ សេវា ចម្បងៗ | សក្តានុពល (ភាពខ្លាំង) | បញ្ហា (ភាពខ្សោយ) | ទំហំបញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការ ធនធាន |
|---|---|---|---|---|---|---|
| វិស័យ សុខាភិបាល៖ សកម្មភាព៖ | | - អត្រាចាក់ថ្នាំបង្ការមានកម្រិតទាប | កុមារអាយុក្រោម ៥ឆ្នាំ | - បុគ្គលិកមណ្ឌលសុខភាពខ្វះខាត | - បណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តផ្នែកសុខភាពនៅសហគមន៍ | |
| ការចាក់ថ្នាំបង្ការឱ្យកុមារអាយុក្រោម ៥ឆ្នាំ | សុខភាពកុមារល្អប្រសើរឡើង | - អត្រាជម្ងឺមានកម្រិតខ្ពស់ (ឧទា៖ ជម្ងឺកញ្ជ្រិល) | ចំនួន ១០០០ នាក់ | - ខ្វះថវិកាទិញថ្នាំចាក់បង្ការ រោគ | - ណែនាំកម្មវិធីចែករំលែកការចំណាយ | |

9

## ផ្នែកសង្គមកិច្ច (២)៖ តារាង២.៣៖ការវិភាគភាពក្រីក្រ

ភាពក្រីក្របណ្ដាលមកពីកត្តា និងមូលហេតុផ្សេងៗជាច្រើន ធ្វើឲ្យមានការពិបាកសម្រាប់អ្នកពាក់ព័ន្ធដែលបានចូលរួម លើកយកមកពិភាក្សាដោយពេញលេញ និងកំណត់ពីទំនាក់ទំនងមូលហេតុទាំងនោះ។ លើសពីនេះ វិធានការដើម្បីដោះស្រាយភាពក្រីក្រ ត្រូវលើកយកពិភាក្សានៅក្នុងផ្នែកនីមួយៗ។ អ្នកពាក់ព័ន្ធ អាចមិនពិភាក្សាការវិភាគបញ្ហាភាពក្រីក្រ លើកលែងតែបញ្ហាទាក់ទង និងភាពក្រីក្រណាមួយ មិនត្រូវបានលើកយកមកពិភាក្សា ក្នុងផ្នែកផ្សេងៗទៀត។

| អត្រាភាពក្រីក្រអំឡុង ៣ឆ្នាំចុងក្រោយ | | | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|---|---|
| ២០០៨ | ២០០៩ | ២០១០ | | | |

10

## ផ្នែកសង្គមកិច្ច (៣)៖ តារាង២.៤៖ការវិភាគអំពីការងារយេនឌ័រ

បញ្ហាយេនឌ័រត្រូវបានធ្វើការវិភាគក្នុងផ្នែកនីមួយៗ ដូចនេះ អ្នកពាក់ព័ន្ធអាចធ្វើការរំលងការវិភាគនេះ លើកលែងតែបញ្ហាសំខាន់ៗណាផ្សេងទៀត ដែលមិនត្រូវបានលើកយកមកពិភាក្សាក្នុងផ្នែកផ្សេងទៀត។

តារាង២.៤៖ ការវិភាគអំពីការងារយេនឌ័រ

| បញ្ហាសំខាន់ៗ | កម្រិតប៉ះពាល់ | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| | | | |

11

## ផែ្នកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ(១)៖ តារាង២.៥

**តារាង ២.៥ ៖ ការវិភាគអំពីការប្រើប្រាស់ដីធ្លី**

១. បំពេញជួរឈរនៃ "ប្រភេទនៃការប្រើប្រាស់ដីធ្លី" និង "ភាគរយនៃការប្រើប្រាស់ដីធ្លី" ពីប្រភពព័ត៌មាន ដូចជាសៀវភៅស្ថិតិប្រចាំឆ្នាំ និង ប្រព័ន្ធផ្ទុកទិន្នន័យនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
*សម្គាល់៖ ទិន្នន័យត្រូវបានណែនាំឲ្យបំពេញទុកជាមុន។*

២. ជ្រើសរើស "វិស័យ និងសកម្មភាពសំខាន់ៗ" ទាក់ទងនឹងការប្រើប្រាស់ដីធ្លី ដែលអ្នកពាក់ព័ន្ធយល់ថាមានសារៈសំខាន់ និងចង់លើកចំនុចទាំងនោះមកដោះស្រាយក្នុងអំឡុងពេល ៥ឆ្នាំខាងមុខ។

12

## ផែ្នកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ(១)៖ តារាង២.៥ (បន្ត)

៣.បំពេញជួរឈរនៃ "បញ្ហា" "មូលហេតុ" និង "ដំណោះស្រាយ" ដោយ ប្រើប្រាស់វិធីសាស្ត្រការវិភាគបញ្ហា និងការវិភាគរកដំណោះស្រាយ។

| ប្រភេទនៃការប្រើប្រាស់ដីធ្លី | ភាគរយនៃការប្រើប្រាស់ដីធ្លី | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|---|---|
| ដីសម្រាប់រស់នៅ និងធ្វើស្រែចំការ | ៧០% នៃដីក្នុងខេត្ត ក | - កើនឡើងជម្លោះពីការកាន់កាប់ដី | - ខ្វះខាតការចុះបញ្ជីដីធ្លី | - ណែនាំប្រព័ន្ធចុះបញ្ជីដីធ្លី | |

13

**ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ(២)៖ តារាង២.៦**

**តារាង២.៦៖ ការវិភាគអំពីធនធានធម្មជាតិ**

១. ជ្រើសរើស និងសរសេរពីប្រភេទធនធានធម្មជាតិដែលអ្នកពាក់ព័ន្ធបានចូលរួម ចង់លើកយកមកពិភាក្សា ដោយយោងទៅតាម
ក).សារៈសំខាន់នៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និង
ខ).ទំហំនៃចំនួនប្រជាជនដែលប្រើប្រាស់ធនធានធម្មជាតិ។
*សម្គាល់៖ មានការបែងចែកធនធានធម្មជាតិជាច្រើនប្រភេទ។ ធនធានធម្មជាតិទូទៅរួមមាន៖ ទឹក ធនធានរ៉ែ ព្រៃឈើ ផលផល សមុទ្រ និងធនធានក្រោមសមុទ្រ។*

២. ជ្រើសរើស "វិស័យ និងសកម្មភាពចម្បង" ដែលទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ ដែលអ្នកពាក់ព័ន្ធចាត់ទុកជាអាទិភាព។

**ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ(២)៖ តារាង២.៦ (បន្ត)**

៣.បំពេញនូវជួរឈរនៃ "សារៈសំខាន់នៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម" ដោយពន្យល់ពីសារៈសំខាន់នៃប្រភេទធនធានធម្មជាតិជាក់លាក់ណាមួយ។ ឧទាហរណ៍ "ព្រៃកោងកាង" អាចចាត់ទុកថាមានសារៈសំខាន់ ពីព្រោះការអភិរក្សធនធានព្រៃកោងកាងមានប្រយោជន៍ សម្រាប់ជីវៈចំរុះ។
៤.បំពេញនូវជួរឈរ "អ្នកអាស្រ័យផលពីធនធានធម្មជាតិ" ដោយពន្យល់ពីរបៀបរស់នៅរបស់ប្រជាជនដែលទទួលឥទ្ធិពលពីធនធានធម្មជាតិ។ឧទាហរណ៍ ប្រជាជនអាចពឹងផ្អែកទៅការនេសាទ ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួន។
៥. បំពេញជួរឈរនៃ "បញ្ហា" "មូលហេតុ" និង "ដំណោះស្រាយ" ដោយប្រើប្រាស់វិធីសាស្ត្រការវិភាគបញ្ហា និងការវិភាគរកដំណោះស្រាយ។

## ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ(២)៖ តារាង២.៦ (បន្ត)

៦. ប្រសិនបើការប្រើប្រាស់ធនធានធម្មជាតិ មានលក្ខណៈមិនស្មើភាពគ្នារវាងបុរស និងស្ត្រី ត្រូវធ្វើការបរិយាយពីតម្រូវការយេនឌ័រ ដើម្បីកែតម្រូវភាពមិនស្មើគ្នានោះ។

| ប្រភេទធនធានធម្មជាតិ | សារៈសំខាន់ក្នុងសេដ្ឋកិច្ចសង្គមកិច្ច | អ្នកអាស្រ័យផល (អ្នកមានមុខរបរចម្បង) | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|---|---|---|
| ព្រៃឈើ | -ប្រភពអុស<br>-ជម្រកសត្វ<br>-ទាក់ទាញភ្ញៀវទេសចរណ៍ | ៣០%នៃប្រជាជនដែលរស់នៅជិតតំបន់ព្រៃឈើ | គ្រោះធម្មជាតិ (ទឹកជំនន់, រាំងស្ងួត..) | ការកាប់បំផ្លាញព្រៃឈើដែលជាជម្រកសត្វព្រៃ | - អប់រំប្រជាពលរដ្ឋឲយល់ពីអត្ថប្រយោជន៍របស់ព្រៃឈើ<br>- ផ្សព្វផ្សាយច្បាប់ការពារព្រៃឈើឲបានទូលំទូលាយដល់ប្រជាពលរដ្ឋ<br>- បង្កើតសហគមន៍ការពារព្រៃឈើឲបានច្រើន | ស្ត្រីចំណាកស្រុកមានបញ្ហាជីវភាព |

## ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ(៣)៖ តារាង២.៧

### តារាង២.៧ ការវិភាគអំពីបរិស្ថាន

១.ជ្រើសរើស និងកត់ត្រាប្រភេទនៃបរិស្ថានក្នុងជួរឈរនៃ "បញ្ហាចម្បង" ដែលអ្នកពាក់ព័ន្ធចាត់ទុកថាមានសារៈប្រយោជន៍ ដោយផ្អែកតាម ក). សារៈសំខាន់នៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និង ខ). ចំនួនប្រជាជនដែលទទួលរងឥទ្ធិពលពីបរិស្ថាន។

*សម្គាល់៖ មានការបែងចែកប្រភេទនៃបរិស្ថានមានច្រើនប្រភេទ ដូចជា ការបំពុលក្នុងបរិយាកាស ទឹកមិនស្អាត ការបំពុលដី លូទឹកស្អុយ កាកសំណល់រឹង និងវត្ថុរាវ សំលេង ក្លិនអាក្រក់ ការស្រុតដី ជាដើម។*

២.បំពេញជួរឈរនៃ "បញ្ហា" "មូលហេតុ" និង "ដំណោះស្រាយ" ដោយប្រើប្រាស់វិធីសាស្ត្រការវិភាគបញ្ហា និងការវិភាគរកដំណោះស្រាយ។

## ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ(៣)៖ តារាង២.៧ (បន្ត)

៣. ប្រសិនបើបញ្ហាបរិស្ថានដែលបានជ្រើសរើសមានបញ្ហាធ្ងន់ធ្ងរក្នុងទស្សនៈយេនឌ័រ គួរពិពណ៌នាពីតម្រូវការយេនឌ័រ។

| បញ្ហាសំខាន់ៗ | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ |
|---|---|---|---|
| ការបោះចោលកាកសំណល់រឹងមិនសមស្រប | - ចំនួនប្រជាជនកើនឡើង<br>- ខ្វះកន្លែងចាក់សម្រាម<br>- ខ្វះរថយន្តដឹកសម្រាម | - សាងសង់កន្លែងចាក់ សម្រាម<br>- ទិញរថយន្តដឹកសម្រាម | |

## ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ(៤)៖ តារាង២.៨

តារាង២.៨៖ ការវិភាគគ្រោះមហន្តរាយ

១. ប្រសិនបើទិន្នន័យមានស្រាប់ សូមបំពេញជួរឈរនៃ "ប្រភេទគ្រោះមហន្តរាយ" ដែលបានកើតឡើងជាក់ស្តែងក្នុង ០៥ ឆ្នាំកន្លងមក និងទំហំនៃការបំផ្លិចបំផ្លាញក្នុងរាជធានី ខេត្ត។

